សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យ

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


រៀបរៀងដោយនិស្សិតឈ្មោះ

**លោក ទ៉ា គាងហុង**

**លោក ហែម មុន្នីជោត**

សាស្ត្រាចារ្យណែនាំ

**លោក ជិន ទណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **វ៉ា គាងហុង** និង **ហែម មុន្នីជោត** ជានិស្សិតផ្នែកនីតិសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសំដែងនូវកត្តញ្ញូតាធម៌ជូនចំពោះលោកឪពុក អ្នកម្តាយ បងប្អូនប្រុសស្រី ដែលបានជួយជ្រោមជ្រែងលើកទឹកចិត្ត ចិញ្ចឹមបីបាច់ថែរក្សាទាំងកំលាំងកាយចិត្ត ក៏ដូចជាបានជួយទំនុកបម្រុងនូវសំភារៈ និងហិរញ្ញវត្ថុដល់រូបខ្ញុំបាទតាំងពីបឋមវ័យរហូតដល់បច្ចុប្បន្ន ។ ម្យ៉ាងវិញទៀត ក៏សូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រីសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានចំណាយពេលដ៏មានតម្លៃ និងយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាល និងចែករំលែក ព្រមទាំងបទពិសោធន៍ដែលលោក លោកស្រីមាន និងធ្លាប់ឆ្លងកាត់មកបង្ហាត់បង្រៀនយើងខ្ញុំដែលជានិស្សិតតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ការសិក្សា ។

សូមអរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្រ្តាចារ្យ **ជិន វណ្ណារ៉ា** ដែលលោកបានទទួលយកយើងខ្ញុំទាំងពីរ ព្រមទាំងចំណាយពេលដ៏មានតម្លៃ ដើម្បីបណ្តុះបណ្តាលនិងពន្យល់ណែនាំដល់យើងខ្ញុំទាំងការយកចិត្តទុកដាក់ផ្នែកគំនិត ប្រាជ្ញា និងផ្តល់ជាកម្លាំងចិត្ត និងយោបល់ផ្សេងៗក្នុងការចងក្រងសារណាបញ្ចប់សារណានេះឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរអ្នកមានគុណទាំងពីរ និងក្រុមគ្រួសារទាំងមូល ព្រមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងលោកសាស្រ្តាចារ្យ ជិន វណ្ណារ៉ា សូមអោយជួបប្រទះនូវសេចក្តីសុខ សេចក្តីចំរើន សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាស្មារតីចងចាំល្អ ជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវសំណាងល្អគ្រប់ពេល ។

# អារម្ភកថា

ការអប់រំ គឺពិតជាចាំបាច់សម្រាប់មនុស្សម្នាក់ៗ ដោយការអប់រំជួយឱ្យបុគ្គលនោះ ក្លាយជាបុគ្គលមានតម្លៃនៅក្នុងសង្គម ក៏ដូចជាធនធានសម្រាប់ប្រទេសជាតិទាំងមូលផងដែរ ។ នៅក្នុងសម័យកាលសកលភាវូបនីយកម្មនេះ ចំណេះដឹងត្រូវបានបង្កើតថ្មីបន្តបន្ទាប់ ដែលធ្វើឱ្យការសិក្សាត្រឹមនៅក្នុងសាលាក្នុងរយៈពេលកំណត់ណាមួយមិនគ្រប់គ្រាន់នោះទេ ដែលតម្រូវឱ្យសិស្ស និស្សិត ត្រូវស្វះស្វែងសិក្សាស្រាវជ្រាវបន្ថែមដោយខ្លួនឯងទៀត ដើម្បីអាចដើរទាន់នូវការផ្លាស់ប្តូរជាបន្តបន្ទាប់ ព្រមទាំងដើរឱ្យទាន់នូវការវិវត្តន៍របស់សង្គមផងដែរ ។ នេះក៏ដូចនៅក្នុងវិស័យគតិយុត្តផងដែរ គ្រប់ប្រទេសតែងមានច្បាប់របស់ខ្លួន ដែលមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ស្របទៅតាមបរិបទរបស់ប្រទេសនីមួយៗ ហើយព្រមទាំងមានការធ្វើវិសោធនកម្មជាបន្តបន្ទាប់ ដើម្បីឱ្យច្បាប់នោះតាមទាន់នូវការផ្លាស់ប្តូរនូវសង្គមជាបន្តបន្ទាប់ ។ ស្របជាមួយគ្នានេះផងដែរ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានដាក់នូវចក្ខុវិស័យរបស់ខ្លួន ដើម្បីក្លាយជាសាកលវិទ្យាល័យដែលឈានមុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាអន្តរជាតិដែលមានគុណភាពខ្ពស់ខាងការអប់រំ ការបង្កើតថ្មី ការស្រាវជ្រាវ និងបោះពុម្ពផ្សាយរបស់សាកលវិទ្យាល័យ ។ ហេតុនេះហើយ ទើបសាកលវិទ្យាល័យនេះបានខិតខំបង្កើតឡើងនូវអ្វីដែលថ្មីសម្រាប់និស្សិតដូចជា បណ្ណាល័យច្បាប់ដែលមានលក្ខណៈធំទូលាយ និងមានសោភ័ណ្ឌភាពសម្រាប់និស្សិតក្នុងការស្វែងរកឯកសារដើម្បីសិក្សាបន្ថែម និងទីកន្លែងសម្រាប់ធ្វើការស្រាវជ្រាវ អាន និងកត់ត្រា ។ ដោយសារតែបែបនេះហើយ ទើបយើងខ្ញុំទទួលបាននូវឱកាសក្នុងការតាក់តែងនូវសារណាមួយនេះឡើងដើម្បីបញ្ចប់នូវការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្ញុំបាន ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងជួយផ្តល់ជាចំណេះដឹង និងធ្វើជាជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់អំពីបណ្តឹងឧបាស្រ័យ ។ យើងខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីអានសារណានេះ ហើយក៏សូមជូនពរឱ្យជួបប្រទះតែសេចក្តីសុខ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច។ សូមអរគុណ!

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម ..................................................... ១**

**ជំពូកទី ១៖ សញ្ញាណទូទៅ ..................................................... ៣**

**ផ្នែកទី ១៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ ..................................................... ៣**

កថាខណ្ឌទី ១៖ ទស្សនៈលើបណ្តឹងឧបាស្រ័យ ..................................................... ៣

កថាខណ្ឌទី ២៖ របបបណ្តឹងឧបាស្រ័យ ..................................................... ៣

**ផ្នែកទី ២៖ អត្ថន័យនៃបណ្តឹងឧបាស្រ័យ ..................................................... ៤**

កថាខណ្ឌទី ១៖ ការប្រើប្រាស់បណ្តឹងឧបាស្រ័យ ..................................................... ៤

កថាខណ្ឌទី ២៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី
និងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ..................................................... ៥

**ជំពូកទី ២៖ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ..................................................... ៦**

**ផ្នែកទី ១៖ បណ្តឹងឧទ្ធរណ៍ ..................................................... ៦**

កថាខណ្ឌទី ១៖ ការធ្វើបណ្តឹងឧទ្ធរណ៍ ..................................................... ៦

កថាខណ្ឌទី ២៖ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ..................................................... ១១

កថាខណ្ឌទី ៣៖ ការវិនិច្ឆ័យ និងការចេញសាលដីកា ..................................................... ១៣

**ផ្នែកទី ២៖ បណ្តឹងសាទុក្ខ ..................................................... ១៩**

កថាខណ្ឌទី ១៖ ការធ្វើបណ្តឹងសាទុក្ខ ..................................................... ២០

កថាខណ្ឌទី ២៖ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា ........ ២៣

**ផ្នែកទី ៣៖ បណ្តឹងជំទាស់ ..................................................... ២៨**

កថាខណ្ឌទី ១៖ ដំណើរការនៃបណ្តឹងជំទាស់ ..................................................... ២៨

កថាខណ្ឌទី ២៖ ប្រភេទដីកាសម្រេចដែលអាចប្តឹងជំទាស់បាន ..................................................... ២៩

កថាខណ្ឌទី ៣៖ វិសាលភាពនៃបណ្តឹងជំទាស់ ..................................................... ៣២

**សេចក្តីសន្និដ្ឋាន ..................................................... ៣៥**

## ឯកសារយោង

## ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ទំនាក់ទំនងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ឬពីគ្រួសារមួយទៅគ្រួសារមួយទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀត រមែងជួបប្រទះនឹងវិវាទមិនអាចជៀសផុតបាន! មិនតែប៉ុណ្ណោះ ទំនាក់ទំនងរវាងកម្មករនិយោជិត និងនិយោជកក៏នៅតែជៀសមិនផុតពីវិវាទផងដែរ ។ យ៉ាងណាមិញ រាស្ត្រ និងមន្ត្រីអាជ្ញាធរគ្រប់ជាន់ថ្នាក់ ក៏នៅតែមានបញ្ហាកើតមានឡើងជារឿយៗ ដូចជាវិវាទដីធ្លី ។ ក្នុងសង្គមគ្រួសារមិនថាឡើយប្តីប្រពន្ធ កូនចៅ មិនប្រាកដថាមានសុភមង្គលបរិបូរណ៍នោះទេ ជម្លោះក្តីក្តាំតែងតែកើតមានដូចជា ការមិនចុះសម្រុងគ្នារវាងប្តីប្រពន្ធ ដែលនាំឱ្យមានជម្លោះរហូតដល់មានការលែងលះគ្នា ។

ដើម្បីស្ងប់ចិត្ត ស្ងប់អារម្មណ៍ រំងាប់នូវជម្លោះក្តីក្តាំ ភាគីនៃជម្លោះតែងតែស្វែងរកដំណោះស្រាយ ។ យន្តការនៃការដោះស្រាយនោះមាន យន្តការនៃការដោះស្រាយវិវាទក្រៅផ្លូវតុលាការ តាមរយៈអាជ្ញាកណ្តាល មានដូចជាមេភូមិ ចៅសង្កាត់ មជ្ឈត្តករការងារ ឬមជ្ឈត្តកម្មពាណិជ្ជកម្ម និងយន្តការដោះស្រាយវិវាទតាមផ្លូវតុលាការ ។ យន្តការចុងក្រោយនេះត្រូវបានច្បាប់រៀបចំផ្តល់សិទ្ធិអំណាចដល់ស្ថាប័ន ៣ រួមមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។

ជាការពិតណាស់ តុលាការដំបូងគឺជាស្ថាប័នដែលស្វែងរកយុត្តធម៌ និងមានតួនាទីដោះស្រាយវិវាទជូនភាគីមុនគេបង្អស់ ប៉ុន្តែបើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដំបូង ភាគីអាចប្តឹងទៅតុលាការជាន់ខ្ពស់ដែលមានតុលាការឧទ្ធរណ៍ និងតុលាការកំពូល ។ ពាក្យចាស់ពោលថា "ប្រទេសមានច្បាប់ គ្រួសារមានវិន័យ" ។ វិធានច្បាប់ និងវិន័យក្នុងគ្រួសារជាឧបករណ៍ដ៏សំខាន់សម្រាប់គ្រប់គ្រងប្រទេសមួយ ឬក្រុមគ្រួសារមួយ ។ យ៉ាងណាមិញ ការអនុវត្តរបស់អ្នកច្បាប់ ចៅក្រម មេធាវី មន្ត្រីតុលាការ ជៀសមិនផុតពីការយកឧបករណ៍ "ច្បាប់" មកធ្វើជាគន្លងផ្លូវដើរតាម ដើម្បីដោះស្រាយក្តីក្តាំជូនភាគីវិវាទដោយយុត្តិធម៌ ។ វិធានដែលត្រូវប្រតិបត្តិដោយស្ថាប័នតុលាការ និងមេធាវី ក្រៅពីច្បាប់សារធាតុ ក៏មានបទបញ្ញត្តិកំណត់ពីនីតិវិធីផងដែរ ។

នីតិវិធីគោលពីរចម្បងក្នុងនីតិវិធីផ្សេងៗទៀតសម្រាប់ដោះស្រាយវិវាទគឺ នីតិវិធិរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌ ។ ដោយសារតែសារណានេះផ្តោតតែទៅលើរដ្ឋប្បវេណីដែលកំណត់យកតែបណដឹងឧបាស្រ័យមកបកស្រាយ នោះនីតិវិធីព្រហ្មទណ្ឌមិនត្រូវបានសិក្សាស្រាវជ្រាវឡើយ ។

សំណោរនេះនឹងបកស្រាយទៅលើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលរួមមាន បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ ។ លើសពីនេះទៅទៀត សំណោរនេះនឹងសិក្សា

ទៅលើឯកសារទាក់ទងនឹងបណ្ដឹងឧបាស្រ័យនៅកម្ពុជាប៉ុណ្ណោះ ។ ដូចដែលយើងដឹងស្រាប់មកហើយថា ការស្រាវជ្រាវមិនអាចខ្វះព័ត៌មានបានឡើយ ។ តែដោយនៅក្នុងសម័យបច្ចេកវិទ្យានេះ ព័ត៌មានអាចប្រមូលយកបានតាមរយៈប្រព័ន្ធអ៊ិនធឺណេត ដែលសម្រួលដល់ការស្រាវជ្រាវមួយនេះ ។ ព័ត៌មានដែលត្រូវបានប្រមូលយកមកតាក់តែងសំណេរនេះ គឺក្រមនីតិវិធីរដ្ឋប្បវេណី និង សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីជាដើម ។ ដូចនេះហើយ ប្រភពនៃការស្រាវជ្រាវក្នុងការតាក់តែងសំណេរនេះកើតចេញពីការអានសៀវភៅ ការសិក្សាកន្លងមក រួមទាំងឯកសារមួយចំនួនដែលបានតម្កល់នៅបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ប្រធានបទនៃបណ្ដឹងឧបាស្រ័យត្រូវបានសរសេរដោយធ្វើការបែងចែកជាពីរជំពូក ។ ជំពូក ១ សញ្ញាណទូទៅ បកស្រាយពី គោលបំណង និង អត្ថន័យនៃបណ្ដឹងឧបាស្រ័យ រីឯ ប្រភេទនៃបណ្ដឹងឧបាស្រ័យ នឹងត្រូវបានបង្ហាញនៅក្នុងជំពូក ២ ។

# ជំពូកទី ១៖ សញ្ញាណទូទៅ

មុននឹងសិក្សាពីបណ្តឹងនីមួយៗនៃបណ្តឹងឧបាស្រ័យ យើងត្រូវស្វែងយល់ពីសញ្ញាណទូទៅនៃបណ្តឹងនេះជាមុនសិន ហេតុនេះហើយគោលបំណង និងអត្ថន័យនៃបណ្តឹងឧបាស្រ័យ នឹងត្រូវបានបកស្រាយនៅខាងក្រោម ។

## ផ្នែកទី ១៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ

នៅក្នុងផ្នែកនេះ នឹងបកស្រាយពីគោលបំណងនៃបណ្តឹងឧបាស្រ័យតាមរយៈ ទស្សនៈលើបណ្តឹងឧបាស្រ័យ និងរបបបណ្តឹងឧបាស្រ័យ ។

### កថាខណ្ឌទី ១៖ ទស្សនៈលើបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងដែលប្តឹងទៅតុលាការជាន់ខ្ពស់ ហើយក៏ជានីតិវិធីមួយដែលចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសអោយប្រើនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៦ ។ ក្រមនីតិវិធីរដ្ឋប្បវេណីចែងអំពីដំណើរការ ឬនីតិវិធីរឿងក្តីរដ្ឋប្បវេណី យ៉ាងណាមិញបណ្តឹងឧបាស្រ័យគឺបង្កើតឡើងក្នុងគោលបំណងរបស់វា(ផ្នែកទី១) និងមានអត្ថន័យ ឬខ្លឹមសារ(ផ្នែកទី២) ដែលមានផលប្រយោជន៍សម្រាប់ជនគ្រប់រូប ។

ចំពោះបណ្តឹងឧបាស្រ័យ គឺធ្វើឡើងដើម្បីលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេច (សាលក្រម សាលដីកា ឬ ដីកាសម្រេច)ដោយភាគីនៃការទាមទារក្នុងបណ្តឹងឧបាស្រ័យ ។ សម្រាប់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ធ្វើបានតែនៅមុនពេលដែលសេចក្តីសម្រេចរបស់តុលាការជាន់ទាបមិនទាន់ចូលជាស្ថាពរទេ[1] ។

ទោះបីជាយើងមិនអាចធ្វើបណ្តឹងឧបាស្រ័យបានក្រោយពេលដែលសេចក្តីសម្រេចចូលជាស្ថាពរ ក៏ប៉ុន្តែយើងអាចធ្វើបណ្តឹងផ្សេងទៀតដើម្បីប្តឹងទៅតុលាការជាន់ខ្ពស់ដូចជា បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

### កថាខណ្ឌទី ២៖ របបបណ្តឹងឧបាស្រ័យ

មនុស្សគឺជាអ្នកសម្រេចក្តីដើម្បីផ្តល់យុត្តិធម៌ដល់ភាគីជម្លោះ ក៏ប៉ុន្តែមនុស្សគ្រប់រូបមិនអាចគេចផុតពីការធ្វើឱ្យមានកំហុសនោះទេ ។ ហេតុនេះហើយបើយើងនៅតែបន្តទុកឲ្យពួកគេធ្វើឱ្យមានកំហុសតទៅទៀតដោយពុំមានយន្តការដោះស្រាយឬកែកំហុសទាំងនោះទេ វានឹងធ្វើអោយប្រជារាស្ត្រទូទៅបាត់បង់នូវជំនឿទុកចិត្តលើតុលាការ ។ យន្តការសម្រាប់ដោះស្រាយបញ្ហានេះគឺ

[1] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មានតែតុលាការជាន់ខ្ពស់តែប៉ុណ្ណោះ ដែលមានអំណាចត្រួតពិនិត្យលើសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម តាមការស្នើសុំរបស់គូភាគីនៃបណ្តឹងឧបាស្រ័យ ។ ល្គឹកណាតុលាការជាន់ខ្ពស់ពិនិត្យទៅមើលឃើញថា សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមមានភាពមិនត្រឹមត្រូវ នោះតុលាការជាន់ខ្ពស់អាចធ្វើការលុបចោល ឬកែប្រែទៅលើសេចក្តីសម្រេចនោះ ។ ចំពោះរបបបណ្តឹងឧបាស្រ័យ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិរបស់ភាគីឲ្យរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យ ឬក្នុងនីតិវិធីនៃការជំនុំជម្រះខុសរបស់តុលាការជាន់ទាប ។ តែទោះជាយ៉ាងនេះក៏ដោយ នីតិវិធីនេះមិនអាចដំណើរការបានឡើយ ប្រសិនបើគ្មានបណ្តឹងទាមទារពីគូភាគីនៃបណ្តឹង ។ ដោយតុលាការថ្នាក់ក្រោមមានច្រើនហេតុនេះធ្វើអោយការអនុវត្តច្បាប់មានការខុសប្លែកគ្នា ក៏ប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយដោយតុលាការកំពូលដែលបានច្របាច់បញ្ចូលគ្នានូវប្រព័ន្ធជំនុំជម្រះក្តីទាំងពីរថ្នាក់ (តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់) ឱ្យដើរស្របទៅតាមគោលការណ៍មួយ ដែលប្រកបទៅដោយស្ថេរភាពមានសណ្តាប់ធ្នាប់ និងប្រកបទៅដោយភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋ ។

## ផ្នែកទី ២៖ អត្ថន័យនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីធ្វើឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ ។ នៅក្នុងផ្នែកនេះផងដែរ ក៏នឹងបកស្រាយពីការប្រើប្រាស់បណ្តឹងឧបាស្រ័យ និងភាពខុសគ្នារបស់បណ្តឹងនេះជាមួយនឹងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

### កថាខណ្ឌទី ១៖ ការប្រើប្រាស់បណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចប្រើប្រាស់បានតែចំពោះសេចក្តីសម្រេចដែលមិនទាន់ចូលជាស្ថាពរនោះទេ ក៏ប៉ុន្តែចំពោះសេចក្តីសម្រេចដែលចូលជាស្ថាពររួចហើយយើងអាចប្រើប្រាស់បណ្តឹងទៅតុលាការដដែល[2] ។

ចំពោះសាលក្រម ឬសាលដីកាគេអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខបាន រីឯដីកាសម្រេចរបស់តុលាការជាន់ទាប លុះត្រាតែមានចែងក្នុងច្បាប់ ទើបគេអាចធ្វើបណ្តឹងជំទាស់បាន ។

[2] បណ្តឹងតុលាការដដែលមានដូចជា បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បណ្តឹងទាស់ និងបណ្តឹងតវ៉ា ។

ប្រសិនបើមានបណ្តឹងឧបាស្រ័យចំពោះសាលក្រមចុងក្រោយរបស់តុលាការជាន់ទាបជាគោលការណ៍ សេចក្តីសម្រេចរបស់តុលាការនោះនៅក្នុងដំណើរការរឿងក្តីរហូតដល់ចេញសាលក្រមចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយនឹងសាលក្រមចុងក្រោយ ។

ប៉ុន្តែចំពោះករណីដែលត្រូវដោះស្រាយអោយបានឆាប់រហ័ស ដើម្បីអោយមានស្ថេរភាពក្នុងដំណើរការនៃនីតិវិធី ប្រសិនបើតុលាការទទួលបណ្តឹងឧបាស្រ័យចំពោះចំណុចបន្ទាប់បន្សំដែលទាក់ទងនឹងដំណើរការនៃនីតិវិធីដោយឡែកនឹងឧបាស្រ័យចំពោះសាលក្រមចុងក្រោយ ដើម្បីដោះស្រាយចំណុចបន្ទាប់បន្សំឱ្យបានចូលជាស្ថាពរឆាប់រហ័សវាមានភាពសមរម្យ ។ ការទទួលស្គាល់ឧបាស្រ័យដោយឡែកនេះ គឺដើម្បីបន្ថយនូវឧបាស្រ័យចំពោះសាលក្រមចុងក្រោយដោយសារតែមានបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ ។

កាលណាភាគីបានធ្វើបណ្តឹងជំទាស់ម្តងរួចទៅហើយលើដីកាសម្រេចដែលមានចែងក្នុងច្បាប់ ភាគីក្នុងបណ្តឹងឧបាស្រ័យនោះមិនអាចធ្វើបណ្តឹងជំទាស់ម្តងទៀតទៅលើដីកាសម្រេចចំពោះបណ្តឹងជំទាស់មុននោះទេ[3] ។

## កថាខណ្ឌទី ២៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី និងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាបណ្តឹងមួយដែលភាគីទាមទារឱ្យតុលាការដែលចេញសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ ធ្វើការលុបចោលសាលក្រម ឬសាលដីកានោះ និងទាមទារឱ្យជំនុំជម្រះរឿងក្តីសាជាថ្មី ដោយយកមូលហេតុថានីតិវិធីនៃបណ្តឹងមានវិការៈ ឬក៏ឯកសារដែលវិនិច្ឆ័យនោះមានភាពខ្វះខាត ។ម្យ៉ាងទៀត បើក្នុងចំណោមដីកាសម្រេចដែលធ្វើឡើងដើម្បីជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី នោះភាគីអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬសាលដីចុងក្រោយ ។

ចំណែកឯបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ អាចធ្វើឡើងបានលុះត្រាតែសាលក្រម ឬសាលដីកា ឬ ដីកាសម្រេចមិនទាន់ចូលជាស្ថាពរតែប៉ុណ្ណោះ ។ លើសពីនេះទៀត មូលហេតុសម្រាប់ការធ្វើបណ្តឹងឧបាស្រ័យគឺភាគីមិនពេញចិត្តនឹងសាលក្រម ឬសាលដីកានោះ ។

[3] មាត្រា ២៥៩ នៃសេចក្តីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី

## ជំពូកទី ២៖ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មាន ៣ ប្រភេទគឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ ។ បណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម និងសាលដីកា រីឯបណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលដីកាសម្រេច[4]។

ហេតុដូច្នេះ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មានប្រភេទផ្សេងៗដែលបែងចែកទៅតាមសេចក្តីសម្រេចដើម ដោយបុគ្គលដែលមានបំណងដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់អាចជ្រើសរើសប្រភេទនៃបណ្តឹងឧបាស្រ័យត្រឹមត្រូវដោយស្របទៅតាមប្រភេទនៃសេចក្តីសម្រេចដើម ។

### ផ្នែកទី ១៖ បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះក្តីលើកទី១ ។ បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូង ។ នេះមានន័យថា មានតែសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់តុលាការដំបូងទេ ដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានទោះជាសាលក្រមចុងក្រោយ ឬសាលក្រមរបៀបក៏ដោយ ។

#### កថាខណ្ឌទី ១៖ ការធ្វើបណ្តឹងឧទ្ធរណ៍

ការធ្វើបណ្តឹងឧទ្ធរណ៍ គឺទាក់ទងទៅនឹងសិទ្ធិក្នុងការធ្វើបណ្តឹង និងរយៈពេលនៃការធ្វើបណ្តឹងនេះ ។ ចំពោះបណ្តឹងឧទ្ធរណ៍នេះមិនចាំបាច់ធ្វើក៏បានដែរប្រសិនបើមានការព្រមព្រៀងរវាងភាគីទាំងពីរជាលាយលក្ខណ៍អក្សរថា មិនធ្វើបណ្តឹងឧទ្ធរណ៍ ឬរឿងក្តីនោះជារឿងក្តីរដ្ឋប្បវេណី ឬរឿងក្តីពាណិជ្ជកម្ម ដែលមានតម្លៃកម្មវត្ថុមិនលើសពី ៥ (ប្រាំ) លានរៀល[5] ។

ម៉្យាងទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ ចេញសាលក្រមកំបាំងមុខ ទោះបីលក្ខខណ្ឌបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ [6] ត្រូវបានបំពេញក៏ដោយ ក៏ភាគីអាចលះបង់ផលប្រយោជន៍ក្នុងការបន្តនីតិវិធីវិនិច្ឆ័យនៅតុលាការថ្នាក់ដដែល ដោយដាក់ពាក្យបណ្តឹង

[4] មាត្រា ២៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[5] មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមដដែល

[6] មាត្រា ២០៤ នៃក្រមដដែល

ទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយក៏អាចធ្វើបណ្តឹងឧទ្ធរណ៍បានដែរ ដោយរង់ចាំការផុតរយៈពេលបណ្តឹងទាស់សិន ។

**១) សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍**

សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ គឺកើតឡើងដោយសារការមិនពេញចិត្តនូវសាលក្រមនៃតុលាការជំបូង ហើយមានតែភាគីដើមបណ្តឹង ឬចុងចម្លើយ ដែលមានប្រយោជន៍នៅក្នុងបណ្តឹងឧបាស្រ័យទេ ទើបមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍បាន ។ តែជាងនេះទៅទៀត ទាល់តែយកខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍របស់ដើមចោទ ឬចុងចម្លើយនៃការជំនុំជម្រះលើកទី ១ មកប្រៀបធៀបនឹងសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយក្នុងករណីដែលសាលក្រមនោះមានផលប្រយោជន៍តូចជាងការទាមទាររបស់ភាគី ទើបផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យត្រូវទទួលស្គាល់ ។ ជាទូទៅអ្នកដែលឈ្នះក្តីទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី ១ គឺគ្មានផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យទេ ដូច្នេះហើយភាគីដែលឈ្នះក្តីនោះគឺគ្មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ទេ ។ ប្រសិនបើភាគីនោះប្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍នោះនឹងត្រូវបានលើកចោល ដោយសារបណ្តឹងឧទ្ធរណ៍នោះផ្ទុយនឹងច្បាប់ ។

សិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍អាចកើតឡើងបានចំពោះភាគីដែលបាត់បង់ផលប្រយោជន៍ពីការជំនុំជម្រះលើកទី ១ តែសិទ្ធិនេះក៏អាចបោះបង់ចោលដែរ[7] ដោយមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្តឹងឧទ្ធរណ៍ នោះសាលក្រមនៃការជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរ ។ ការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្តឹងឧទ្ធរណ៍ គឺខុសពីការព្រមព្រៀងគ្នាថាផ្លោះទៅប្តឹងសាទុក្ខ ពីព្រោះការព្រមព្រៀងបែបនេះគឺសាលក្រមនៃការជម្រះលើកទី១ មិនទាន់ចូលជាស្ថាពរទេទោះហួសរយៈពេលប្តឹងក៏ដោយ ។ ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងតាមសេចក្តីថ្លែងការណ៍ ។ តែបើភាគីលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ក្រោយពេលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ សេចក្តីថ្លែងការណ៍ស្តីពីការបោះបង់សិទ្ធិប្តឹងឧទ្ធរណ៍ និងការដកពាក្យបណ្តឹងត្រូវធ្វើជាមួយគ្នា[8] ។

**២) អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍**

បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងក្នុងរយៈពេល ១ ខែ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូនលិខិតសាលក្រម (លិខិតដែលបញ្ជាក់រាល់ចំណុចដែលបានសម្រេចសេចក្តីក្នុងសាលក្រម) នៃការជំនុំជម្រះលើកទី ១ ឬពីថ្ងៃដែលដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខត្រូវបានជូនដំណឹង ហើយរយៈពេលនេះមិនអាចពន្យារបានឡើយ ។

[7] មាត្រា ២៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[8] មាត្រា ២៦៣ កថាខណ្ឌទី២ នៃក្រមដដែល

ប្រសិនបើអំឡុងពេលមួយខែនោះបានកន្លងហួសទៅ ដែលជាមូលហេតុមួយមិនសមស្របចំពោះអ្នកចាញ់ក្តីដោយសាលក្រមកំបាំងមុខធ្វើឲ្យជននោះមិនអាចប្តឹងឧទ្ធរណ៍បានទេ ។

ក៏ប៉ុន្តែ ទោះបីជាមានករណីខាងលើក៏ដោយក៏ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍នៅតែអាចធ្វើបណ្តឹងឧទ្ធរណ៍បាន ដោយគ្រាន់តែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដូចធម្មតាក្នុងរយៈពេលមួយសប្តាហ៍គិតពីថ្ងៃដែលមូលហេតុដែលធ្វើឱ្យខកខាននោះបានរលត់ ហើយមូលហេតុនោះពុំមែនជាកំហុសរបស់ភាគីនោះទេ ។ ជាងនេះទៅទៀត ភាគីនោះក៏ត្រូវតែបញ្ជាក់ និងអះអាងអំពីមូលហេតុ និងភស្តុតាងដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ឱ្យបានច្បាស់លាស់ ។

**៣) របៀបធ្វើបណ្តឹងឧទ្ធរណ៍**

ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ ភាគីត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើមដែលជាតុលាការនៃការជំនុំជម្រះលើកទី១ ។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍នេះ ភាគីត្រូវតែបញ្ជាក់អំពីឈ្មោះ អាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ ហើយភាគីក៏ត្រូវសរសេរនូវសញ្ញាណសាលក្រមនៃការជំនុះជម្រះលើកទី ១ និងសេចក្តីនៃការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។ម្យ៉ាងវិញទៀត នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ភាគីត្រូវសរសេរ ឱ្យបានក្បោះក្បាយអំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬឱ្យផ្លាស់ប្តូរនូវសាលក្រមដើមនៃការជំនុំជម្រះលើកទី ១ ប្រសិនបើភាគីមិនបានសរសេរ ច្បាស់លាស់នូវមូលហេតុនៃការទាមទារនោះទេ វានឹងធ្វើឱ្យតុលាការនៃបណ្តឹងឧទ្ធរណ៍ពិបាកក្នុងការស្វែងរកចំណុចវិវាទនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស ។

អ្នកធ្វើបណ្តឹងឧទ្ធរណ៍ក៏អាចដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នេះ ។ ពាក្យបណ្តឹងឧទ្ធរណ៍នេះត្រូវដាក់ទៅតុលាការដើមដែលបានធ្វើការជំនុំជម្រះលើកទី ១ ហើយពេលដែលបានទទួលពាក្យបណ្តឹងឧទ្ធរណ៍នេះហើយ តុលាការនៃការជំនុំជម្រះលើកទី ១ នេះត្រូវតែផ្ញើពាក្យបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស[៦] ។ ដូចនេះ នៅពេលដែលទទួលបានបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវពិនិត្យពាក្យបណ្តឹងនោះ ហើយប្រសិនបើពិនិត្យទៅឃើញថាមានចំណុចខ្វះខាត តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ ហើយបង្គាប់ឱ្យភាគីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងនោះ ។ ក៏ប៉ុន្តែក្នុងករណីដែលភាគីពុំបានធ្វើការកែតម្រូវចំណុចខ្វះខាតទាំងនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច ។ តុលាការនៃបណ្តឹងឧទ្ធរណ៍ក៏អាចលើកចោលពាក្យបណ្តឹង

[៦] មាត្រា ២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឧទ្ធរណ៍នេះដោយដីកាសម្រេចដូចគ្នា ក្នុងករណីដែលដើមបណ្តឹងឧទ្ធរណ៍មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍នេះ[10] ។

ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍ពិនិត្យទៅឃើញថាពាក្យបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅឱ្យចុងចម្លើយបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែក្នុងករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ទៅចុងបណ្តឹងឧទ្ធរណ៍បានទេ ឬ ករណីដែលភាគីមិនបានបង់ប្រាក់ប្រដាប់ក្តីដែលចាំបាច់ដើម្បីបញ្ជូនបណ្តឹងឧទ្ធរណ៍ ត្រូវអនុលោមតាមករណីដែលពាក្យបណ្តឹងមិនត្រឹមត្រូវទម្រង់ច្បាប់[11] ។

**៤) អានុភាពនៃការដាក់ពាក្យបណ្តឹង**

នៅពេលដែលភាគីធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនៃសាលាដំបូង បណ្តឹងឧទ្ធរណ៍នោះរមែងមានអានុភាពទៅលើសាលក្រមដូចជា អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម អានុភាពនៃការផ្ទេរការជម្រះក្តី និង ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ដែលនឹងរៀបរាប់នៅចំណុចខាងក្រោមនេះ ។

**៤.១. អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម**

ពេលដែលភាគីបានធ្វើបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលដែលកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍ ទោះបីជាអំឡុងពេលដែលកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍នោះបានកន្លងផុតទៅហើយក៏ដោយក៏សាលក្រមដើមមិនអាចចូលជាស្ថាពរបានឡើយ ឬការចូលស្ថាពរត្រូវបានបង្អាក់[12] ។ ការមិនអាចចូលជាស្ថាពរ ឬការបង្អាក់ការចូលជាស្ថាពរនេះគេហៅថា "អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃការប្តឹងឧទ្ធរណ៍" ។ មិនតែប៉ុណ្ណោះ អានុភាពអនុវត្តសាលក្រមក៏មិនអាចកើតមានដែរ ប្រសិនបើសាលក្រមដើមនោះ ពុំមានភ្ជាប់ជាមួយនឹងការប្រកាសអនុវត្តជាបណ្តោះអាសន្ន ឬអាជ្ញាអស់ជំនុំពុំទាន់កើតឡើង ដែលមានចែងនៅក្នុងមាត្រា ១៩៥ និង មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[10] មាត្រា ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[11] មាត្រា ២៦៧ កថាខណ្ឌទី ២ នៃក្រមដដែល

[12] មាត្រា ១៩៣ កថាខណ្ឌ ២ នៃក្រមដដែល

### ៤.២. អានុភាពនៃការផ្ទេរការជម្រះក្ដី

នៅពេលដែលមានបណ្ដឹងឧទ្ធរណ៍ ការចាត់ការនៃការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ នេះគេហៅថាអានុភាពនៃការផ្ទេរការជម្រះក្ដីដោយបណ្ដឹងឧទ្ធរណ៍ ។ ដោយសារអានុភាពនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យនៃការទាមទារនោះ ។

### ៤.៣. ភាពអវិភាគនៃបណ្ដឹងឧទ្ធរណ៍

អានុភាពទាំងពីរខាងលើនេះអាចមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃការជម្រះក្ដីលើកទី ១ គឺក្នុងករណីដែលភាគីប្ដឹងមិនសុខចិត្តលើផ្នែកណាមួយនៃសាលក្រម ក៏ប៉ុន្តែការធ្វើបណ្ដឹងឧទ្ធរណ៍នឹងធ្វើឱ្យចំណុចទាំងអស់ ព្រមទាំងចំណុចដែលបានឯកភាពនៅក្នុងសាលក្រមជំនុំជម្រះលើកទី ១ មិនមានអានុភាពក្នុងការអនុវត្តឡើយ (អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម) ។

ទោះបីជាអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រមធ្វើឱ្យសាលក្រមទាំងមូលមិនអាចចូលជាស្ថាពរ តែមាត្រា ២៧១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ បានកំណត់ថាដើមបណ្ដឹងឧទ្ធរណ៍អាចដាក់ពាក្យសុំទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍សុំឱ្យប្រកាសនូវការអនុវត្តជាបណ្ដោះអាសន្នទៅលើផ្នែកណាមួយនៃសាលក្រមដើម ដែលចុងចម្លើយបណ្ដឹងឧទ្ធរណ៍មិនបានធ្វើបណ្ដឹងបន្ទាប់បន្សំទៅលើផ្នែកនៃសាលក្រម ។

ម្យ៉ាងទៀតក្នុងចំណោមសាលក្រមដើម ចំពោះផ្នែកដែលដើមបណ្ដឹងឧទ្ធរណ៍មិនបានធ្វើបណ្ដឹងឧទ្ធរណ៍ ភាគីមិនចាំបាច់ធ្វើការទាញហេតុផលឡើយ[13] ។ លើសពីនេះទៅទៀត តុលាការក៏មិនអាចផ្លាស់ប្ដូរការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើមបានដែរ [14] ប៉ុន្តែការវិនិច្ឆ័យអំពីផ្នែកនោះក៏មិនត្រូវចូលជាស្ថាពរដោយឯកឯងបានដែរ ។ ហើយចំពោះផ្នែកណាមួយនៃការទាមទារនៃសាលក្រមដើមនឹងត្រូវចូលជាស្ថាពរបើសិនជាភាគីមានការព្រមព្រៀងគ្នាថាមិនប្ដឹងឧទ្ធរណ៍ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍និងសិទ្ធិប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះផ្នែកនោះ ។

[13] មាត្រា ២៧២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[14] មាត្រា ២៧៨ នៃក្រមដដែល

### ៥) ការដកពាក្យបណ្តឹង

មិនថាបណ្តឹងរដ្ឋប្បវេណីប្រភេទណានោះទេ គឺដើមបណ្តឹងអាចដកពាក្យបណ្តឹងវិញបាន ។ ដូចគ្នាផងដែរ សម្រាប់ពាក្យបណ្តឹងឧទ្ធរណ៍ ភាគីនៃដើមបណ្តឹងឧទ្ធរណ៍អាចដកពាក្យបណ្តឹងឧទ្ធរណ៍វិញបានរហូតដល់ពេលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាស[15] ។ ក៏ប៉ុន្តែ ការដកពាក្យបណ្តឹងមួយផ្នែកគឺមោឃៈ ដោយសារគោលការណ៍ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ។

ការដកពាក្យបណ្តឹងឧទ្ធរណ៍ ធ្វើឱ្យបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាមិនបានចាត់ការនៅតុលាការនៃបណ្តឹងឧទ្ធរណ៍តាំងពីដំបូង ។ ដោយការដកពាក្យបណ្តឹងឧទ្ធរណ៍ ធ្វើអោយសាលក្រមនៃការជំនុំជម្រះលើកទី ១ ចូលជាស្ថាពរនៅពេលដែលអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស ។ ប៉ុន្តែបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍បានហួសហើយ នោះសាលក្រមនៃតុលាការជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរភ្លាម ។ ការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍អាចធ្វើដោយផ្ទាល់មាត់បាន[16] ។ ការដកពាក្យបណ្តឹងនេះ គឺមិនចាំបាច់មានការយល់ព្រមពីចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍ទេ ពីព្រោះគ្មានផលប្រយោជន៍ ។ មិនតែប៉ុណ្ណោះ ក្រោយពេលដកពាក្យបណ្តឹងបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍មិនទាន់ហួសទេ ភាគីដើមបណ្តឹង ឬភាគីចុងចម្លើយអាចដាក់បណ្តឹងឧទ្ធរណ៍បានទៀត ។

## កថាខណ្ឌទី ២៖ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាបណ្តឹងដែលចុងចំលើយនៃបណ្តឹងឧទ្ធណ៍អាចដាក់អមជាមួយនឹងបណ្តឹងឧទ្ធរណ៍ដើម្បីទាមទារផលប្រយោជន៍ដែលខ្លួនបានបាត់បង់ក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១ ។

ចុងចម្លើយបណ្តឹងឧទ្ធរណ៍អាចឆ្លៀតឱកាសនេះដើម្បីធ្វើបណ្តឹងឧបាស្រ័យទាមទារអោយផ្លាស់ប្តូរនូវផ្នែកនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលខ្លួនបានបាត់បង់ផលប្រយោជន៍ឲ្យទទួលនូវផលប្រយោជន៍នោះវិញ [17] ។ នេះជាយន្តការមួយការពារភាគីម្ខាងទៀតពីការខាតបង់ប្រយោជន៍

---

[15] មាត្រា ២៦៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[16] មាត្រា ២៦៩ នៃក្រមដដែល

[17] មាត្រា ២៧០ នៃក្រមដដែល

ពីស្ថានភាពនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ បានទទួលស្គាល់នូវការទាមទារមួយភាគ ឬ ច្រានចោលនូវការទាមទារមួយភាគរបស់ដើមបណ្តឹង ហើយប្រសិនបើភាគីណាមួយគិតឃើញថា បើភាគីម្ខាងទៀតស្កប់ចិត្តនឹងសាលក្រមនោះ ខ្លួនក៏មិនប្តឹងឧទ្ធរណ៍ដែរ ។

ឧទាហរណ៍ នៅក្នុងការជំនុំជម្រះលើកទី ១ ដើមបណ្តឹងបានទាមទារចុងចម្លើយសងនូវប្រាក់ចំនួន ១០០$ តែតុលាការបានចេញសាលក្រមទទួលស្គាល់តែចំនួន ៧០$ ដោយច្រានចោលចំនួន ៣០$ ហើយចុងចម្លើយបានប្តឹងឧទ្ធរណ៍នៅក្នុងកំឡុងពេលដែលអាចធ្វើទៅបាន ។ ដោយយោងទៅតាមគោលការណ៍ហាមឃាត់មិនឲ្យផ្លាស់ប្តូរអ្វីដែលខូចប្រយោជន៍ [18] តុលាការអាចជំនុំជម្រះដោយបង្គាប់ឲ្យសងតាមសាលដីកាបានត្រឹមតែចំនួន ៧០$ ឬក្រោមចំនួន ៧០$ តែប៉ុណ្ណោះ ។ ប៉ុន្តែបើចុងចម្លើយបណ្តឹងឧទ្ធរណ៍ប្តឹងឧទ្ធរណ៍បន្ទាប់បន្សំទៅលើចំនួន ៣០$ ដែលជាផ្នែកដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានច្រានចោលនោះ តុលាការបណ្តឹងឧទ្ធរណ៍អាចចេញសាលដីកាបង្គាប់ឲ្យដើមបណ្តឹងឧទ្ធរណ៍សងនូវចំនួន ១០០$ នោះក៏បានដែរ ។

តាមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ទំហំនៃឧបាស្រ័យដែលត្រូវបានវិនិច្ឆ័យនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានពង្រីក ។ ដូចនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យមិនមែនតែអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ទេ ប៉ុន្តែគឺត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឧបាស្រ័យរបស់ចុងចម្លើយបណ្តឹងឧទ្ធរណ៍ផងដែរ ។ ក្នុងករណីដែលមានតែដើមបណ្តឹងឧទ្ធរណ៍ដែលធ្វើឧបាស្រ័យ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចផ្លាស់ប្តូរសាលក្រមដើមដោយខូចខាតប្រយោជន៍ចំពោះដើមបណ្តឹងឧទ្ធរណ៍ដោយហួសទំហំនៃសាលក្រមដើមបានឡើយ ។ ក៏ប៉ុន្តែប្រសិនបើមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពីចុងចម្លើយបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើការផ្លាស់ប្តូរ។

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាការធ្វើបណ្តឹងឧបាស្រ័យដោយភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀតចំពោះចំណុចដែលភាគីនោះមិនបានប្តឹងឧទ្ធរណ៍ដោយខ្លួនឯង ។ នៅត្រង់នេះប្រសិនបើបណ្តឹងឧទ្ធរណ៍ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះគ្មានទេ វាក៏នឹងអស់អានុភាពដែរ ។ តែបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងក្នុងអំឡុងពេលដែលអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ ហើយមានគ្រប់គ្រាន់នូវលក្ខខណ្ឌផ្សេងៗទៀតនៃបណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

[18] មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នោះនឹងក្លាយជាបណ្តឹងឧទ្ធរណ៍ដែលឯករាជ្យវិញ[19] គឺចង់បញ្ជាក់ថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះនឹងក្លាយទៅជាបណ្តឹងឧទ្ធរណ៍តែម្តង ។

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំអាចធ្វើបានតែមុនពេលដែលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ ។ ទោះបីជាចុងចម្លើយបណ្តឹងឧទ្ធរណ៍លះបង់សិទ្ធិប្តឹងឧទ្ធរណ៍ ឬទោះបីជាអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួសសម្រាប់ចុងចម្លើយបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏ចុងចម្លើយបណ្តឹងឧទ្ធរណ៍នោះអាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។

របៀបធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ត្រូវអនុលោមតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ [20] ។ ហេតុដូច្នេះដើមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (ចុងចម្លើយបណ្តឹងឧទ្ធរណ៍) ត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ បន្ទាប់មកតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ហើយត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅដើមបណ្តឹងឧទ្ធរណ៍[២១] ។

## កថាខណ្ឌទី ៣៖ ការវិនិច្ឆ័យ និងការចេញសាលដីកា

ក្រោយពីបានធ្វើ និងដាក់បណ្តឹងហើយ នីតិវិធីបន្ទាប់គឺនីតិវិធីដែលតុលាការទទួលបណ្តឹងត្រូវវិនិច្ឆ័យ និងចេញដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដែលនឹងរៀបរាប់បន្តទៅនេះ ។

### ១) នីតិវិធីជម្រះលើបណ្តឹងឧទ្ធរណ៍

ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យរកភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវនៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមជំនុំជម្រះលើកទី ១ ហើយជាមួយគ្នានេះដែរត្រូវពិនិត្យឡើងវិញលើអង្គហេតុ និងអង្គច្បាប់ចំពោះការទាមទារនៃការជំនុំជម្រះលើកទី ១ ទៅតាមទំហំដែលចាំបាច់ដើម្បីវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការប្តឹងឧបាស្រ័យនោះ ។ ក៏ប៉ុន្តែ តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងមិនចាត់ការរឿងក្តីសារឡើងវិញទាំងស្រុងតាំងពីដំបូងមក ដោយមិនគិតដល់ការជំនុំជម្រះលើកទី ១ នោះទេ ។ ទោះជាយ៉ាងណាក្តី តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងបន្តការជំនុំជម្រះនេះដោយផ្អែកលើធនធានដែលបានប្រមូលនៅក្នុងការជំនុំជម្រះលើកទី ១ និងបន្ថែមនូវធនធានថ្មីផ្សេងទៀត ហើយបន្ទាប់មកនឹងធ្វើការវិនិច្ឆ័យថាតើគួររក្សាទុកនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានឬទេ ។

---

[19] ឯករាជ្យក្នុងន័យនេះ មានន័យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក្លាយជាបណ្តឹងឧទ្ធរណ៍ពេញលេញដោយមិនចាំបាច់ដាក់អមនិងបណ្តឹងឧទ្ធរណ៍ទៀតទេ

[20] មាត្រា ២៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[21] មាត្រា ២៦៥ ដល់មាត្រា ២៦៧ នៃក្រមដដែល

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឧបាស្រ័យចំពោះសាលក្រមដើម ហើយទំហំនៃឧបាស្រ័យនោះត្រូវបានកំណត់ដោយបណ្តឹងរបស់ដើមបណ្តឹងឧទ្ធរណ៍ និងចុងចម្លើយបណ្តឹងឧទ្ធរណ៍ ។

បញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាចំពោះការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍[22] ។ មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ អនុញ្ញាតឱ្យតុលាការនៃបណ្តឹងឧទ្ធរណ៍លើកចោលបណ្តឹងនោះដោយសាលដីកា ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ប្រសិនបើបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបាន ។ ដើម្បីចេញសាលដីកាដែលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការប្តឹងឧបាស្រ័យដោយបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់[23] ។

ដោយសារកម្មវត្ថុចម្បងនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧទ្ធរណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវធ្វើត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឲ្យផ្លាស់ប្តូរនូវសាលក្រមដើមនៃការជំនុំជម្រះលើកទី ១ ទេ ។ លើសពីនេះទៅទៀត ដោយសារនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចៅក្រមត្រូវផ្លាស់ប្តូរពីចៅក្រមនៃការជំនុំជម្រះលើកទី ១ ហេតុនេះហើយ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១[24] ។ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបន្តធ្វើការវិនិច្ឆ័យដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ម្តងរួចហើយនៅក្នុងការជំនុំជម្រះលើកទី ១ ។ ហេតុដូចនេះ សកម្មភាពបណ្តឹងដែលត្រូវបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ ក៏មានអានុភាពនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ ដែលមានចែងក្នុងមាត្រា ២៧៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ។ ការធ្វើសេចក្តីថ្លែងការណ៍នេះត្រូវបានធ្វើឡើងដើម្បីយកលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ មកបង្ហាញនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ហេតុនេះហើយការធ្វើសេចក្តីថ្លែងការណ៍នេះ

---

[22] មាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[23] មាត្រា ១១៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[24] មាត្រា ២៧២ នៃក្រមដដែល

គឺគ្រាន់តែជាសកម្មភាពរាយការណ៍ដែលមានលក្ខណៈជាទម្រង់ ដើម្បីបំពេញគោលការណ៍វិនិច្ឆ័យដោយផ្ទាល់តែប៉ុណ្ណោះ[25] ។

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីត្រូវបានផ្តល់នូវឱកាសដើម្បីដាក់មធ្យោបាយតទល់ ឬការពារខ្លួនដែលខ្លួនមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី ១ ។ ម៉្យាងទៀត ប្រសិនបើភាគីត្រូវបានអនុញ្ញាតអោយដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយគ្មានកម្រិតទេនោះ មានការបារម្ភថានឹងបណ្តាលអោយមានការយឺតយ៉ាវចំពោះនីតិវិធី ដោយសារភាគីមិនខិតខំប្រឹងប្រែងធ្វើការទាញហេតុផលនៅក្នុងការជំនុំជម្រះលើកទី ១ ទេ ដោយមើលស្រាលចំពោះនីតិវិធីនៃការជំនុំជម្រះលើកទី ១ តែបែរជាយកចិត្តទុកដាក់ជាខ្លាំងចំពោះការជំនុំជម្រះបណ្តឹងឧទ្ធរណ៍វិញ ។

ហេតុដូច្នេះ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ប្រសិនបើភាគីដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយមានការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យទៅតាមដំណើរការនៃនីតិវិធីដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងរ មធ្យោបាយនោះអាចត្រូវបានលើកចោល[26] ។ ក្នុងករណីនេះ មិនមែនតែដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ទេ គឺដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ ក៏ត្រូវយកមកពិចារណាដើម្បីវិនិច្ឆ័យពីភាពមិនត្រឹមត្រូវនឹងពេលសមរម្យដែរ ។

### ២) ការចេញដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

បន្ទាប់ពីបានវិនិច្ឆ័យលើបណ្តឹងរួចរាល់ហើយ តុលាការត្រូវចេញដីកានៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដូចជា សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ និង សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ដែលនឹងបកស្រាយខាងក្រោមនេះ ។

### ២.១. សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍

ជាគោលការណ៍ ការវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍ថាត្រឹមត្រូវតាមច្បាប់ ឬអត់នោះត្រូវតែមានការបើកការទាញហេតុផលដោយផ្ទាល់មាត់[27] ប៉ុន្តែចំពោះបណ្តឹងដែលមិនអាចកែតម្រូវចំណុចខ្វះខាតបានដូចជាករណីដែលបណ្តឹងឧទ្ធរណ៍នោះបានប្តឹងនៅក្រោយពេលដែលបានកំណត់អោយប្តឹងឧទ្ធរណ៍ជាដើម ទោះជាមានការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ក៏វាមិនអាចបានផលប្រយោជន៍អ្វីឡើយ ។ ហេតុដូច្នេះ ក្នុងករណីនេះតុលាការអាចលើកចោលបណ្តឹងឧទ្ធរណ៍ដោយ

[25] មាត្រា ១៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[26] មាត្រា ២៧៣ និងមាត្រា ៩៤ នៃក្រមដដែល

[27] មាត្រា ១១៤ នៃក្រមដដែល

សាលដីកា ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ ។ តែចំពោះសិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ និងការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ គឺត្រូវលើកពាក្យបណ្តឹងឧទ្ធរណ៍ចោលដោយដីកាសម្រេចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍[28] ។

## ២.២. សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍

នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មានភាពត្រឹមត្រូវ ទោះបីជាសំអាងហេតុនៃសាលក្រមនោះមិនត្រឹមត្រូវក៏តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះដែរ ព្រោះគ្មានមូលហេតុក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ [29] ។

បើទំហំនៃអាជ្ញាអស់ជំនុំមានត្រឹមតែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់ចំពោះការទាមទារដែលបានសុំដោយពាក្យបណ្តឹង ឬពាក្យបណ្តឹងតប អានុភាពនៃអាជ្ញាអស់ជំនុំនេះមិនអាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមនោះទេ[30] ។ ហេតុដូច្នេះតុលាការនៃបណ្តឹងឧទ្ធរណ៍មិនចាំបាច់ធ្វើសាលដីកាដែលរក្សាទុកសេចក្តីសម្រេចបញ្ចប់នៃការជំនុំជម្រះលើកទី ១ ដោយគ្រាន់តែប្តូរនូវមូលហេតុឡើយ ។ ដូចនេះហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចច្រានចោលបណ្តឹងឧទ្ធរណ៍បាន ។ ក្នុងករណីដែលអានុភាពនៃអាជ្ញាអស់ជំនុំនេះមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាសសាលដីកាដែលមានសេចក្តីសម្រេចបញ្ចប់ដូចនឹងសាលក្រមដើមដោយប្តូរនូវសំអាងហេតុ ។

ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ តាមមាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ ក៏តុលាការត្រូវច្រានចោលពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះដែរ ។

ប្រសិនបើសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ សាលក្រមដើមក៏ត្រូវចូលជាស្ថាពរដែរ ។ ក្នុងករណីនេះប្រសិនបើសាលក្រមដើមជាសាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក សាលក្រមដើមក្លាយទៅជាលិខិតអនុវត្ត នេះបើតាមមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ។

[28] មាត្រា ២៦៦ និង មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29] មាត្រា ២៧៧ កថាខណ្ឌទី ១ នៃក្រមដដែល

[30] មាត្រា ២៧៧ កថាខណ្ឌទី ២ និងមាត្រា ១៩៤ នៃក្រមដដែល

## ២.៣. សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍

នៅក្នុងករណីដែលការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ មានមូលហេតុត្រឹមត្រូវ ហើយសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬប្រសិនបើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ខុសច្បាប់ធ្ងន់ធ្ងរ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចយកនីតិវិធីនៃការជំនុំជម្រះលើកទី ១ នោះមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ[31] ។ ការលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ មានន័យថា តុលាការមិនឆ្លើយតបទៅនឹងបណ្តឹងដែលបានប្តឹង តុលាការត្រូវចាត់វិធានការសមរម្យដូចតទៅ ៖

### ២.៣.១. ការលុបចោល និង ការជំនុំជម្រះដោយខ្លួនឯង

ដោយសារការជំនុំជម្រះបណ្តឹងឧទ្ធរណ៍គឺជាការវិនិច្ឆ័យលើអង្គហេតុ ជាគោលការណ៍ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមរបស់សាលាដំបូង តុលាការនៃបណ្តឹងឧទ្ធរណ៍នោះត្រូវវិនិច្ឆ័យទៅលើបណ្តឹងនោះជំនួសសាលាដំបូង[32] ។

- ក្នុងករណីនេះសេចក្តីបញ្ចប់នៃសាលដីកាមាន ២ យ៉ាងគឺ៖

ទី១-ការលុបចោលសាលក្រមដើម និង ច្រានចោលការទាមទាររបស់ដើមចោទ

ទី២-កែប្រែ ឬផ្លាស់ប្តូរសាលក្រមដើម ដោយបញ្ចូលគ្នានូវការលុបចោល និង ការវិនិច្ឆ័យដោយខ្លួនឯង ។

### ២.៣.២. ការលុបចោល និងការបញ្ជូនត្រឡប់នៅវិញ

ក្នុងករណីដែលទទួលស្គាល់លើបណ្តឹងឧទ្ធរណ៍ ហើយលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ ការប្តឹងរបស់ដើមចោទនឹងត្រឡប់ទៅស្ថានភាពដែលគ្មានការឆ្លើយតបវិញ ។ ហេតុនេះនៅក្រោមប្រព័ន្ធបន្តការវិនិច្ឆ័យ ជាគោលការណ៍តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះដោយខ្លួនឯងទៅលើការទាមទារនោះថាតើត្រឹមត្រូវ ឬអត់ ។ ប៉ុន្តែនៅក្នុងករណីដែលសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹងដោយខ្វះលក្ខខណ្ឌនៃបណ្តឹង នោះអាចមានករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានវិនិច្ឆ័យទៅលើអង្គហេតុពុំបានគ្រប់គ្រាន់ទេ ហេតុដូចនេះដើម្បីរក្សាផលប្រយោជន៍របស់ភាគីនៅដំណាក់កាលវិនិច្ឆ័យ ពោលគឺ

[31] មាត្រា ២៧៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32] មាត្រា ២៧៩ កថាខណ្ឌទី ២ នៃក្រមដដែល

ដើម្បីធានាទៅលើឱកាសដែលអាចធ្វើនីតិវិធីបាន ២ ដង ក្នុងការវិនិច្ឆ័យរឿងពិត ទម្រាំទៅដល់ការវិនិច្ឆ័យនៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ។ ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍បញ្ជូនត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញ (សាលាដំបូង) ហើយធ្វើនីតិវិធីនោះសាជាថ្មីឡើងវិញ ។ ប៉ុន្តែក្នុងករណីដែលការវិនិច្ឆ័យទៅលើអង្គហេតុនោះគ្រប់គ្រាន់ហើយ ឬក្នុងករណីដែលគូភាគីពុំមានវិវាទអំពីទំនាក់ទំនងនៃអង្គហេតុទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ពុំចាំបាច់បញ្ជូនត្រឡប់ទៅវិញឡើយ ។

ចំពោះសាលដីកាបញ្ជូនរឿងក្តីត្រលប់ទៅវិញអាចប្តឹងសាទុក្ខបាន ។ នៅពេលដែលសាលដីកាបញ្ជូនរឿងក្តីត្រឡប់ទៅវិញចូលជាស្ថាពរ រឿងក្តីនោះនឹងត្រូវផ្ទេរទៅតុលាការដើម (តុលាការជំនុំជម្រះលើកទី១) បន្ទាប់មកសាលាដំបូងនឹងត្រូវបន្តនីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមក ។ នីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមកនៅតែមានអានុភាព លើកលែងតែនីតិវិធីនោះត្រូវបានយល់ឃើញថាផ្ទុយនឹងច្បាប់នៅក្នុងសំអាងហេតុ ដែលនាំអោយមានការលុបចោលសាលក្រមដើម (ក្នុងសាលដីកា)[33] ។

### **២.៣.៣. ការលុបចោល និងផ្ទេររឿងក្តី**

ក្នុងករណីដែលបានលុបចោលនូវសាលក្រមរបស់សាលាដំបូង ដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ ដោយមិនចាំបាច់បញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដែលបានចេញសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ[34] ។ ទោះបីជាខុសសមត្ថកិច្ចផ្តាច់មុខក៏ដោយក៏រឿងនេះ មិនអាចក្លាយទៅជាមូលហេតុនៃការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែរ ។

## **២.៤. វិសាលភាពនៃការលុបចោល និង ការផ្លាស់ប្តូរ**

តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលុបចោល ឬផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានត្រឹមតែកម្រិតនៃឧបាស្រ័យដោយបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ភាគីតែប៉ុណ្ណោះ[35] ។ នេះគឺជាការតំណាងចំពោះគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី ដែលមាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានកំណត់ថា តុលាការត្រូវចេញសាលក្រមតែចំពោះ

---

[33] មាត្រា ២៨០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[34] មាត្រា ២៨១ នៃក្រមដដែល

[35] មាត្រា ២៧៨ នៃក្រមដដែល

ការទាមទាររបស់ភាគីនោះទេ គឺមិនអាច ចេញសាលក្រមចំពោះចំណុចដែលភាគីពុំបានសុំឡើយ ក៏ប៉ុន្តែតុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ។ ហេតុនេះហើយ ចំពោះភាគីដែលមិនមានប្តឹងឧបាស្រ័យទេ ទោះបីជាសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ក៏ដោយ ក៏មិនអាចផ្លាស់ប្តូរនូវការវិនិច្ឆ័យបានដែរ ហើយក៏មិនអាចចេញសាលដីកាដែលផ្តល់នូវផលប្រយោជន៍ជាងសាលក្រមនៃការជំនុំជម្រះលើកទី ១ ឲ្យហួសពីទំហំនៃបណ្តឹងឧបាស្រ័យបានដែរ (គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយផ្តល់ផលប្រយោជន៍) ។

ជាឧទាហរណ៍ ប្រសិនបើចុងចម្លើយដែលចាញ់ក្តីចំពោះបណ្តឹងដើម និងបណ្តឹងតបបានប្តឹងឧទ្ធរណ៍ចំពោះតែសាលក្រមនៃបណ្តឹងតបតែប៉ុណ្ណោះ ទោះបីជាតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃបណ្តឹងដើមមិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចវិនិច្ឆ័យអំពីសាលក្រមនៃបណ្តឹងដើមបានឡើយ ។ ម្យ៉ាងទៀត ប្រសិនបើមិនមានបណ្តឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀត ឬមិនមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពីភាគីម្ខាងទៀតទេ ជាគោលការណ៍ ដើមបណ្តឹងឧទ្ធរណ៍មិនអាចទទួលនូវសាលដីកាដែលខាតបង់ប្រយោជន៍ជាងអ្វីដែលបានសម្រេចនៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ បើយ៉ាងច្រើនបំផុត បណ្តឹងឧទ្ធរណ៍នោះគ្រាន់តែបានច្រានចោលប៉ុណ្ណោះទេ (គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍) ។ ទោះបីជាមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក៏ដោយ ដើមបណ្តឹងឧទ្ធរណ៍អាចរួចផុតពីការផ្លាស់ប្តូរដោយខូចខាតប្រយោជន៍បានដោយដកពាក្យបណ្តឹងឧទ្ធរណ៍[36] ។

គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយផ្តល់ផលប្រយោជន៍ និងគោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតប្រយោជន៍ត្រូវអនុវត្តចំពោះតែទំហំដែលតុលាការត្រូវបានចងដោយពាក្យសុំរបស់ភាគីប៉ុណ្ណោះ[37] ។ ហេតុដូចនេះ ការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីជាដើម ដែលអាចធ្វើដោយឆន្ទានុសិទ្ធិរបស់តុលាការមិនត្រូវទទួលឥទ្ធិពលពីពាក្យសុំរបស់ភាគីឡើយ ។

## **ផ្នែកទី ២៖ បណ្តឹងសាទុក្ខ**

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ដែលទាមទារអោយវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវចំពោះការអនុវត្តច្បាប់នៃសាលក្រម ឬសាលដីកាចុងក្រោយ ។ មាត្រា

[36] មាត្រា ២៧០ កថាខណ្ឌទី ២ នៃក្រមដដែល

[37] មាត្រា ១៨២ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃក្រមដដែល

២៨៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានកំណត់ថា បណ្ដឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។ ក៏ប៉ុន្តែក្នុងករណីដែលមានការព្រមព្រៀងស្ដីពីការប្ដឹងសាទុក្ខផ្លោះទៅតុលាការកំពូល និងក្នុងករណីដែលសាលាឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្ដឹងសាទុក្ខដោយផ្ទាល់បានចំពោះសាលក្រម ឬសាលដីកានៃតុលាការនៃការជំនុំជម្រះលើកទី ១[38] ។

គោលដៅនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ គឺការពារភាគីដែលទទួលរងនូវការខូចខាតប្រយោជន៍ពីការជំនុំជម្រះដែលមិនត្រឹមត្រូវ ។ លើសពីនេះទៅទៀត ការជំនុំជម្រះបណ្ដឹងសាទុក្ខក៏មានគោលដៅធ្វើអោយមានការឯកភាពចំពោះការបកស្រាយច្បាប់ ដោយធ្វើការវិនិច្ឆ័យចំពោះសាលដីកាចុងក្រោយដែលចេញដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ជាអាទិ៍ ។

ការជំនុំជម្រះបណ្ដឹងសាទុក្ខ គឺជាការវិនិច្ឆ័យលើអង្គច្បាប់ ប៉ុន្តែមានលក្ខណៈរួមគ្នាជាច្រើននឹងបណ្ដឹងឧទ្ធរណ៍ ។ ហេតុនេះហើយ មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានកំណត់ថា បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ និងនីតិវិធីបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបណ្ដឹងសាទុក្ខ និងនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ។

## កថាខណ្ឌទី ១៖ ការធ្វើបណ្ដឹងសាទុក្ខ

នៅក្នុងកថាខណ្ឌស្ដីពីការធ្វើបណ្ដឹងសាទុក្ខនេះ នឹងធ្វើការបកស្រាយអំពី នីតិវិធីនៃបណ្ដឹងសាទុក្ខ និង លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ ។

### ១) នីតិវិធីបណ្ដឹងសាទុក្ខ

ដើម្បីប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម ។ តុលាការដើមត្រូវផ្ញើឲ្យបានឆាប់រហ័សនូវពាក្យបណ្ដឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ [39] ។ តុលាការនៃបណ្ដឹងសាទុក្ខដែលបានទទួលពាក្យបណ្ដឹងសាទុក្ខ ត្រូវពិនិត្យពាក្យបណ្ដឹងសាទុក្ខ ហើយប្រសិនបើពាក្យបណ្ដឹងនោះមានចំណុចខ្វះខាត តុលាការត្រូវលើកចោលពាក្យបណ្ដឹងសាទុក្ខនោះដោយដីកាសម្រេច[40] ។ ប៉ុន្តែប្រសិនបើពិនិត្យទៅឃើញថាពាក្យបណ្ដឹងនោះត្រឹមត្រូវហើយ មាត្រា ២៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កំណត់ឱ្យតុលាការនៃបណ្ដឹងសាទុក្ខបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខទៅដើមបណ្ដឹងសាទុក្ខ និងចុងចម្លើយបណ្ដឹងសាទុក្ខ ។ ប្រសិនបើមាន

[38] មាត្រា ២៨៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[39] មាត្រា ២៨៧ នៃក្រមដដែល

[40] មាត្រា ២៨៦ និងមាត្រា ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចំណុចខ្វះខាតនៅក្នុងពាក្យបណ្តឹងសាទុក្ខ ឬលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខត្រូវបង្គាប់អោយធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ ។ តាមមាត្រា ២៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ក្នុងករណីដែលដើមបណ្តឹងសាទុក្ខមិនបានកែតម្រូវចំណុចខ្វះខាតក្នុងអំឡុងពេលនោះ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច ។

ជាគោលការណ៍ អំឡុងពេលដែលអាចធ្វើបណ្តឹងសាទុក្ខបានគឺ ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រម ឬសាលដីកាដើម ដូចអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ដែរ[41] ។ ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានដាក់ អានុភាពបង្អាក់នូវការចូលជាស្ថាពរ និងអានុភាពនៃការផ្ទេរសមត្ថកិច្ចជម្រះក្តីត្រូវកើតឡើងចំពោះសាលដីកាដើម ឬសាលក្រមដើម ។ ក្នុងចំណោមសាលដីកាដើម ឬសាលក្រមដើម ទោះបីជាមានផ្នែកណាមួយដែលគ្មានឧបាស្រ័យក៏ដោយ ក៏ផ្នែកនោះមិនត្រូវចូលជាស្ថាពរដែរ ។ ក៏ប៉ុន្តែ មាត្រា ២៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានកំណត់ថា តុលាការនៃបណ្តឹងសាទុក្ខអាចប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន ចំពោះផ្នែកដែលគ្មានឧបាស្រ័យតាមពាក្យសុំដោយដីកាសម្រេចបាន ។ ម្យ៉ាងទៀតចុងបណ្តឹងសាទុក្ខ ក៏អាចដាក់ពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំបានដែរ[42] ។

ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខជូនទៅតុលាការនៃបណ្តឹងសាទុក្ខក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ប្រសិនបើខ្លួនមិនបានសរសេរអំពីមូលហេតុនោះនៅក្នុងពាក្យបណ្តឹងសាទុក្ខទេ ។ ក្នុងករណីដែលប្តឹងសាទុក្ខដោយយកមូលហេតុថា ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកាដើម ដើមបណ្តឹងសាទុក្ខត្រូវសរសេរនូវបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តនោះ ព្រមទាំងហេតុដែលមានភាពផ្ទុយនឹងបញ្ញត្តិនោះក្នុងពាក្យបណ្តឹងសាទុក្ខ ឬលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ។ ហើយបើប្តឹងសាទុក្ខ ដោយសារមាន "មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ" ដូចមានចែងក្នុងមាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលនឹងបកស្រាយនៅចំណុច ៣ ខាងក្រោម ដើមបណ្តឹងត្រូវសរសេរនូវបញ្ញត្តិច្បាប់និងអង្គហេតុដែលត្រូវនឹងមូលហេតុដាច់ខាតនោះ[43] ។

[41] មាត្រា ២៨៦ និងមាត្រា ២៦៤ នៃក្រមដដែល

[42] មាត្រា ២៨៦ និងមាត្រា ២៧០ នៃក្រមដដែល

[43] មាត្រា ២៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

**២) លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ**

តាមកំណត់មាត្រា ២៨៤ នៃសេចក្ដីពីន្យលក្រមនីតិវិធីរដ្ឋប្បវេណី ទំព័រ ២៦១ បណ្ដឹងសាទុក្ខត្រូវមានលក្ខខណ្ឌស្របច្បាប់មួយចំនួនដូចជា ៖

១. សេចក្ដីសម្រេចដើមមានលក្ខណៈអាចប្ដឹងសាទុក្ខបាន (មិនអាចប្ដឹងសាទុក្ខចំពោះសាលក្រមរបៀប ឬចំពោះដីកាសម្រេចដែលចេញនៅមុនពេលចេញសាលដីកា (សាលក្រម) សម្រេចអង្គសេចក្ដី ដោយឯករាជ្យដាច់តែឯងបានទេ ។ ប្រសិនបើមានការខកខានក្នុងការសម្រេចសេចក្ដីនូវការទាមទារ ណាមួយ តុលាការត្រូវចេញសាលដីកា (សាលក្រម) បន្ថែមទៀត គេមិនអាចប្ដឹងសាទុក្ខបានទេ) ។

២. មានការដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដែលមានសមត្ថកិច្ច ។

៣. ពាក្យបណ្ដឹងសាទុក្ខ និងលិខិតបញ្ជាក់ពីមូលហេតុនៃបណ្ដឹងសាទុក្ខ ត្រូវបានធ្វើទៅតាមទម្រង់ស្របច្បាប់ ហើយត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ទៅតុលាការនៃបណ្ដឹងសាទុក្ខ ។

៤. មានសុពលភាពទៅលើការដាក់ និងការបញ្ជូនពាក្យបណ្ដឹង ជាអាទិ៍ ។

៥. ដើមបណ្ដឹងសាទុក្ខមានសេចក្ដីឧបាស្រ័យចំពោះការសម្រេចសេចក្ដីរបស់តុលាការដើម ។

៦. ដើមបណ្ដឹងសាទុក្ខមិនបានបោះបង់ចោលនូវសិទ្ធិប្ដឹងសាទុក្ខរបស់ខ្លួន ឬមិនបានព្រមព្រៀងមិនប្ដឹងសាទុក្ខ ។

៧. មិនបានធ្វើបណ្ដឹងសាទុក្ខត្រួតគ្នា ។

៨. មិនបានបំពានសិទ្ធិប្ដឹងសាទុក្ខ ។

៩. មានលក្ខខណ្ឌនៃបណ្ដឹងត្រឹមត្រូវ ។

**៣) មូលហេតុនៃបណ្ដឹងសាទុក្ខ**

មូលហេតុសម្រាប់ប្ដឹងសាទុក្ខត្រូវបានកំណត់ច្បាស់លាស់ ហេតុនេះភាគីមិនអាចធ្វើបណ្ដឹងសាទុក្ខបានដោយគ្រាន់តែលើកមូលហេតុនៃការខាតប្រយោជន៍របស់ខ្លួននៅក្នុងសាលដីកាដើមទេ ។ មូលហេតុដែលអាចលើកយកមកប្ដឹងសាទុក្ខបានមានតែពីរយ៉ាងតែប៉ុណ្ណោះគឺ មូលហេតុទូទៅ និងមូលហេតុដាច់ខាត ។

មូលហេតុទូទៅដែលអាចលើកយកមកធ្វើបណ្តឹងសាទុក្ខបានគឺ ភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម [44]។ ក្នុងករណីដែលមានមូលហេតុនេះមែន តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលនូវសាលដីកាដើម ឬសាលក្រមដើម ។ ផ្ទុយទៅវិញ ប្រសិនបើគ្មានមូលហេតុទូទៅទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ ។ ដូចនេះ អត្ថិភាពនៃមូលហេតុដើម្បីប្តឹងសាទុក្ខ មិនមែនជាលក្ខខណ្ឌស្របច្បាប់ដើម្បីដាក់បណ្តឹងសាទុក្ខទេ តែវាជាមូលហេតុនៃការបដិសេធចោលនូវសាលដីកាដើម ។

សម្រាប់មូលហេតុដាច់ខាត ប្រសិនបើមានការធ្វើផ្ទុយនឹងនីតិវិធីសំខាន់ៗ ភាគីមិនចាំបាច់ធ្វើការបញ្ជាក់ថា ភាពផ្ទុយនឹងនីតិវិធីនេះមានឥទ្ធិពលទៅលើសាលដីកា ឬសាលក្រមទេ ។ មូលហេតុដាច់ខាតនៃការធ្វើបណ្តឹងសាទុក្ខត្រូវបានកំណត់ច្បាស់លាស់ដូចតទៅ៖

១. តុលាការដែលចេញសាលដីកា ឬសាលក្រម មិនត្រូវបានចាត់តាំងដោយស្របទៅតាមច្បាប់ ។

២. ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬសាលក្រម តែបានចូលរួម ។

៣. ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ។

៤. ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង ។

៥. ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ។

៦. សាលដីកា ឬសាលក្រម គ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយគ្នា[45] ។

## កថាខណ្ឌទី ២៖ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា

ក្រោយពីតុលាការឧទ្ធរណ៍ចេញសាលដីការួចលើបណ្តឹងរបស់ភាគី បើភាគីនៅតែមិនយល់ស្របលើសេចក្តីសម្រេចនោះ ភាគីអាចធ្វើការប្តឹងមកតុលាការកំពូលដែលជាតុលាការចុងក្រោយនៃការជំនុំជម្រះក្តី ។ ហើយនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា នឹងធ្វើការបកស្រាយនៅចំណុចខាងក្រោម ។

[44] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[45] មាត្រា ២៨៥ កថាខណ្ឌទី ១ នៃក្រមដដែល

### ១) នីតិវិធីជម្រះនៃបណ្តឹងសាទុក្ខ

- ការលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច

តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច ប្រសិនបើបណ្តឹងសាទុក្ខនោះមានបញ្ហាដូចដែលមានចែងក្នុងមាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូចជាបណ្តឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបាន ឬប្រសិនបើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមិនត្រូវបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ ឬ មូលហេតុនៃបណ្តឹងមិនត្រឹមត្រូវ ។ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខមិនបានចេញសាលដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខទេ ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខទៅចុងបណ្តឹងសាទុក្ខ ហើយត្រូវផ្តល់ឱកាសឲ្យចុងចម្លើយសាទុក្ខដាក់ឯកសារត្រៀម[46] ។ មាត្រា ២៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានបញ្ជាក់ថា តុលាការនៃបណ្តឹងសាទុក្ខត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលដីកាដើម ឬសាលក្រមដើមត្រឹមតែកម្រិតនៃឧបាស្រ័យតែប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របនឹងច្បាប់ ។

- ការច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកា

នៅក្នុងការជំនុំជម្រះទៅលើអង្គសេចក្តី តុលាការត្រូវពិនិត្យមើលទៅលើឯកសារជាលាយល័ក្ខណ៍អក្សរដែលមានដូចជា លិខិតពាក្យបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និងឯកសារផ្សេងៗទៀត ។ ដោយផ្អែកលើឯកសារទាំងអស់នោះ ប្រសិនបើតុលាការយល់ឃើញថាគ្មានមូលហេតុប្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខអាចចេញសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខនោះ ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ។ ទោះជាក្នុងករណីដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ប្រសិនបើពិនិត្យទៅឃើញថា ពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ[47] ។

ចំណែកឯការទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវសម្រាប់ការធ្វើបណ្តឹងសាទុក្ខ តុលាការត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីកាដើម[48] ។ ការបដិសេធចោល មានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់លុបចោលនូវសាលដីកាដើម ឬសាលក្រមដើម ។ ដូចនេះតុលាការនៃ

---

46 មាត្រា ២៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

47 មាត្រា ២៨៦ និងមាត្រា ២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

48 មាត្រា ២៩៩ កថាខណ្ឌទី ១ នៃក្រមដដែល

បណ្តឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលបដិសេដចោលនូវសាលដីកាដើម ឬសាលក្រមដើម ។

**២) ការបដិសេដចោលដោយបញ្ជូនទៅតុលាការដើមវិញ**

ជាគោលការណ៍ ក្រោយការបដិសេដចោលនូវសាលក្រម ឬសាលដីកាដើម តុលាការពុំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្តីទេ ដូច្នេះហើយករណីនេះ ខុសពីករណីនៃការលុបចោលនូវសាលក្រមដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីទៅតុលាការដើមវិញ ។ ជាបឋម ក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសាជាថ្មី មិនអាចធ្វើការជំនុំជម្រះជំនួសសាលក្រមដើម ឬសាលដីកាដើមទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដើមវិញ ឬក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រឡប់នោះមិនសមស្របទេ ដោយសារមានការកម្រិតនៃកថាខណ្ឌទី ៣ មាត្រា ២៩៩ ថាមិនអនុញ្ញាតឱ្យចៅក្រមដែលពាក់ព័ន្ធនឹងសាលក្រមដើម ឬសាលដីកាដើម ចូលរួមជំនុំជម្រះរឿងក្តីនោះម្តងទៀតទេ ដែលត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ស្មើគ្នា ។ ឧទាហរណ៍ តុលាការជំនុំជម្រះលើកទី ១ មិនមានសមាសភាពចៅក្រមផ្សេងទៀតដែលមិនទាន់បានជម្រះលើបណ្តឹងនោះ ដូចនេះត្រូវបញ្ជូនទៅតុលាការផ្សេងទៀតដែលមានថ្នាក់ស្មើគ្នាក្នុងការជម្រះវិញម្តង ។ តុលាការដែលបានទទួលនូវការបញ្ជូនត្រឡប់មកវិញ ឬដែលបានទទួលការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្តងទៀត[49] ។ ការទាញហេតុផលដោយផ្ទាល់មាត់នោះ ជាសារធាតុ គឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក ។ ប៉ុន្តែចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់នេះទេ ។ ហេតុដូចនេះភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក[50] ។

ក្នុងករណីនេះ សេចក្តីវិនិច្ឆ័យទៅលើអង្គច្បាប់ និងអង្គហេតុដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេដចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរ[51] ។ នេះគឺដោយសារតែ បើតុលាការដើមនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬនៅតែធ្វើការចាត់ចែងដូចមុនដដែល ទោះជាតុលាការនៃបណ្តឹងសាទុក្ខបានបញ្ជូនត្រឡប់ទៅវិញប៉ុន្មានដងក៏ដោយ ក៏រឿងក្តីនោះ

[49] មាត្រា ២៩៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមដដែល
[50] មាត្រា ១៨៥ កថាខណ្ឌទី ២ និងអនុវត្តផងដែរនូវមាត្រា ២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[51] មាត្រា ២៩៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមដដែល

មិនអាចដោះស្រាយចប់បានឡើយ ។ សេចក្ដីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិតតែសេចក្ដីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្ដឹងសាទុក្ខអាចវិនិច្ឆ័យបានដូចជាអង្គហេតុដែលទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ ។ អានុភាពចងនៃសេចក្ដីវិនិច្ឆ័យលើអង្គច្បាប់មានន័យថា តុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរនោះមិនអាចធ្វើសេចក្ដីវិនិច្ឆ័យអំពីចំណុចពាក់ព័ន្ធនឹងអង្គច្បាប់ដែលសេចក្ដីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់ក្នុងសាលដីកាដើម ឬសាលក្រមដើមនោះ បានក្លាយទៅជាមូលហេតុនៃការបដិសេធចោល ។ ហេតុនេះអានុភាពនេះតម្រូវអោយតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរជៀសវាងធ្វើការវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះ តែមិនហាមឃាត់អោយតុលាការនោះចេញសាលដីកា ឬសាលក្រម ដែលមានសេចក្ដីសន្និដ្ឋានដូចគ្នានឹងសាលដីកា ឬសាលក្រមមុន ដោយយកការបកស្រាយផ្សេងនូវអង្គច្បាប់ទេ ។

ដើម្បីធានានូវអានុភាពចងការវិនិច្ឆ័យនោះបាន ចៅក្រមណាដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រមដើមដែលត្រូវបានបដិសេធចោល មិនត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការសម្រេចសេចក្ដីក្រោយនោះបានទេ[52] ។ ដើម្បីកុំអោយមានឧបសគ្គជាក់ស្ដែងដោយសារការកម្រិតនេះ ច្បាប់អនុញ្ញាតអោយផ្ទេររឿងក្ដីជំនួសការបញ្ជូនត្រលប់វិញ ។

**៣) ការបដិសេធចោល ហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង**

តុលាការនៃបណ្ដឹងសាទុក្ខដែលបានបដិសេធចោលនូវសាលដីកាដើម (ឬសាលក្រមដើមក្នុងករណីដែលមានការព្រមព្រៀងផ្លោះទៅបណ្ដឹងសាទុក្ខ ជាតទៅពន្យល់តែករណីដែលមានបណ្ដឹងសាទុក្ខចំពោះសាលដីការបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះ) អាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលដីកាដើមនោះបានក្នុងករណីដែលអាចចេញសាលដីកាជំនួសសាលដីកានោះបានដោយផ្អែកលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលដីកាដើម[53] ។ សាលដីកាដែលជំនួសសាលដីកាដើម គឺជាចម្លើយចំពោះពាក្យបណ្ដឹងឧទ្ធរណ៍ ហេតុនេះមានករណីខ្លះដែលមិនឆ្លើយផ្ទាល់ចំពោះបណ្ដឹងនៃការជំនុំជម្រះលើកទី ១ ដែរ ។ ករណីដែលតុលាការនៃបណ្ដឹងសាទុក្ខវិនិច្ឆ័យដោយខ្លួនឯង និងចេញសាលដីកាជំនួសសាលដីកាដើមមានករណីដូចតទៅ៖

១. ជាដំបូង មានករណីដែលតុលាការនៃបណ្ដឹងសាទុក្ខទទួលស្គាល់បណ្ដឹងឧទ្ធរណ៍ និងលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយបញ្ជូនរឿងក្ដីត្រឡប់ទៅតុលាការនៃការ

---

[52] មាត្រា ២៩៩ កថាខណ្ឌទី ៣ នៃក្រមដដែល

[53] មាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ជំនុំជម្រះលើកទី ១ ឬផ្ទេររឿងក្តីទៅតុលាការនៃការជំនុំជម្រះលើកទី ១ ។ ក្នុងចំណោមករណីនេះ មាន ២ ករណីទៀតគឺ៖

ក. ករណីដែលសាលដីកាដើមដែលត្រូវបានបដិសេធចោល រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលច្រានចោលការទាមទារ ឬរក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ ។

ខ. ករណីដែលគួរតែឲ្យវិនិច្ឆ័យឡើងវិញពីការជំនុំជម្រះលើកទី ១ ដោយសារការជំនុំជម្រះលើកទី ១ ពីមុននោះមិនគ្រប់គ្រាន់ ។

២. ក្រៅពីករណីខាងលើ មានករណីដែលតុលាការនៃបណ្តឹងសាទុក្ខលើកចោល ឬច្រានចោលបណ្តឹងឧទ្ធរណ៍ ឬករណីដែលទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និងចេញសាលដីកាផ្ទាល់ចំពោះបណ្តឹង (លើកចោលបណ្តឹង ច្រានចោលការទាមទារ ឬទទួលស្គាល់ការទាមទារ) ។

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធចោលសាលដីកាដើម ដោយហេតុថា សាលដីកាដើមនោះមានកំហុសនៅក្នុងការអនុវត្ត ឬបកស្រាយច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ចំពោះអង្គហេតុដែលត្រូវបានកំណត់ជាស្ថាពរ ហើយប្រសិនបើអាចសម្រេចសេចក្តីអំពីអង្គហេតុចំពោះរឿងក្តីនោះបាន ដោយកែតម្រូវការអនុវត្ត ឬបកស្រាយច្បាប់ ឬបទដ្ឋានគតិយុត្តនោះឲ្យបានត្រឹមត្រូវ៖

- បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ តុលាការនៃបណ្តឹងសាទុក្ខនឹងច្រានចោលបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។
- បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ តុលាការនៃបណ្តឹងសាទុក្ខនឹងលុបចោលសាលក្រមនោះ ហើយសម្រេចដោយខ្លួនឯងថា ទទួលស្គាល់ ឬច្រានចោលការទាមទារ[54] ។

ម្យ៉ាងទៀតក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបដិសេធសាលដីកាដើម ដោយហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ [55] ប្រសិនបើសាលក្រមនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍ ហើយប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ បានចេញសាលក្រមសម្រេចអង្គសេចក្តីវិញ តុលាការនៃបណ្តឹងសាទុក្ខត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះនិងត្រូវលើកចោលបណ្តឹងដោយខ្លួនឯង ។

[54] មាត្រា ៣០០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[55] មាត្រា ៣០០ កថាខណ្ឌទី ២ នៃក្រមដដែល

## ផ្នែកទី ៣៖ បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្តីសម្រេច ។ នីតិវិធីនៃបណ្តឹងជំទាស់មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេច ។ ដូចនេះយើងឃើញថា បណ្តឹងជំទាស់ខុសពីការតវ៉ាដែលជាឧបាស្រ័យចំពោះដីកាសម្រេចទៅតុលាការសាមី ។

### កថាខណ្ឌទី ១៖ ដំណើរការនៃបណ្តឹងជំទាស់

ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់បណ្តឹងជាមុនសិន ដែលត្រូវឆ្លងកាត់នូវដំណើរការនៃបណ្តឹងជំទាស់ដូចជា ការធ្វើបណ្តឹងជំទាស់ និង នីតិវិធីនៃការជម្រះក្តីលើបណ្តឹងជំទាស់ ដែលនឹងធ្វើការរៀបរាប់ដូចខាងក្រោមនេះ ។

**១) ការធ្វើបណ្តឹងជំទាស់**

ផលប្រយោជន៍ក្នុងការប្តឹងជំទាស់ត្រូវបានទទួលស្គាល់ចំពោះភាគី ឬតតិយជនដែលបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចដើម ។ បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ។ ក្នុងអំឡុងពេលនេះមិនអាចពន្យារពេលបានទេ [56] ។ ដើម្បីធ្វើបណ្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងពាក្យបណ្តឹងជំទាស់ គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬការផ្លាស់ប្តូរដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះក៏បណ្តឹងជំទាស់នៅតែមានសុពលភាពដែរ ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់មិនបានសរសេរនូវមូលហេតុនោះទេ ដើមបណ្តឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីពេលដែលបានដាក់នូវពាក្យបណ្តឹងជំទាស់នោះ[57] ។ ពេលដែលបានទទួលនូវពាក្យបណ្តឹងជំទាស់ហើយ តុលាការនៃបណ្តឹងជំទាស់ត្រូវពិនិត្យពាក្យបណ្តឹងជំទាស់នោះ ហើយប្រសិនបើមានចំណុចណាមិនស្របនឹងទម្រង់ ត្រូវបង្គាប់ឲ្យដើមបណ្តឹងជំទាស់ធ្វើការកែតម្រូវ ។ ក៏ប៉ុន្តែបើភាគីនោះមិនធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេ មាត្រា ៣០៤ កថាខណ្ឌទី ១

[56] មាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[57] មាត្រា ៣០១ កថាខណ្ឌទី ២ នៃក្រមដដែល

និងមាត្រា ២៦៦ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កំណត់ឱ្យតុលាការត្រូវលើកចោលបណ្ដឹងជំទាស់នោះដោយដីកាសម្រេច ។

### ២) នីតិវិធីនៃការជម្រះក្ដីលើបណ្ដឹងជំទាស់

នីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេច ដូចនេះតុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានថាតើត្រូវការទាញហេតុផលដោយផ្ទាល់មាត់ ឬទេ[58] ។ ក្នុងករណីដែលមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ មាត្រា ៣០៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ អនុញ្ញាតឱ្យតុលាការនៃបណ្ដឹងជំទាស់អាចសួរម្ចាស់បណ្ដឹងជំទាស់ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងផលប្រយោជន៍នឹងបណ្ដឹងជំទាស់នោះបាន ។ ក្នុងការជំនុំជម្រះបណ្ដឹងជំទាស់ ភាគីអាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មី ដូចជាការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ដែរ ។ តាមមាត្រា ២៥៩ កថាខណ្ឌទី ៣ នៃក្រមដដែល បានបង្ហាញឱ្យឃើញថា សេចក្ដីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្ដឹងជំទាស់ គឺជាដីកាសម្រេច ហើយខ្លឹមសារនៃដីកាសម្រេចនោះ ត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ ។ ក៏ប៉ុន្តែចំពោះបណ្ដឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យនិងខ្លឹមសារនៃសេចក្ដីសម្រេចចុងក្រោយត្រូវអនុលោមទៅតាមករណីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់[59] ។

## កថាខណ្ឌទី ២៖ ប្រភេទដីកាសម្រេចដែលអាចប្ដឹងជំទាស់បាន

មាត្រា ២៥៩ កថាខណ្ឌទី ២ បានចែងថា "បណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់" ។ ជាទូទៅដីកាសម្រេច ទាំងឡាយណាដែលធ្វើឡើងដោយតុលាការអំពីចំណុចដែលបានក្លាយទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីរហូតចេញសាលក្រម ឬសាលដីកាចុងក្រោយត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយ ដោយបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ[60] ។ ក៏ប៉ុន្តែបើសិនជាគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនីតិវិធីឬដែលកើតឡើងដោយនីតិវិធីនៃការជំនុំជម្រះសុទ្ធតែដាក់ឲ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះនឹងធ្វើឱ្យរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឲ្យមានភាពយឺតយ៉ាវក្នុងការជំនុំជម្រះរឿង

[58] មាត្រា ៣០៦ កថាខណ្ឌទី ១ និងមាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[59] មាត្រា ៣០៤ នៃក្រមដដែល

[60] មាត្រា ២៦២ នៃក្រមដដែល

ក្តីនោះ ។ ដូច្នេះជាការល្អ ប្រសិនបើឲ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្តីនៃរឿងក្តី ហើយត្រូវការសម្រេចឲ្យឆាប់ ដោះស្រាយបានដោយនីតិវិធីសង្ខេបដែលធ្វើឡើងដាច់ដោយឡែក ។ ម្យ៉ាងទៀតក្នុងករណីដែលបញ្ចប់នីតិវិធីដោយដីកាសម្រេច (ដូចជា ការសម្រេចលើកចោលពាក្យបណ្តឹង មាត្រា ៧៨ កថាខណ្ឌទី ២) ឬក្នុងករណីដែល តុលាការចេញដីកាសម្រេចចំពោះតតិយជនក្រៅពីភាគី (ដូចជាដីកាសម្រេចបង្គាប់ឲ្យតតិយជនផ្តល់ឯកសារ មាត្រា ១៥២ កថាខណ្ឌទី ៣) វាចាំបាច់ដែលត្រូវបើកផ្លូវឲ្យតតិយជននោះ ដែលចង់ធ្វើឧបាស្រ័យចំពោះដីកាសម្រេច អាចធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។

ដីកាសម្រេចដែលអាចប្តឹងជំទាស់បានមាន ៣ ប្រភេទដូចខាងក្រោម ៖

**ក. ដីកាសម្រេចបដិសេធ**

- ដីកាសម្រេចឲ្យលុបចោលដីកាសម្រេចជួយសង្គ្រោះលើពាក្យបណ្តឹង (មាត្រា ៧០ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលុបចោលប្រាតិភោគ (មាត្រា ៧៣ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកបណ្តឹងចោល (បណ្តឹងទាស់[61] បណ្តឹងឧទ្ធរណ៍[62]) (មាត្រា ៧៨ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកចោលពាក្យសុំឲ្យរក្សាការពារភស្តុតាង (មាត្រា ១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង (មាត្រា ១៧៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងច្រានចោលការទាមទារឲ្យជំនុំជម្រះសាជាថ្មី (មាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន (មាត្រា ៣២៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលុបចោលនូវការរឹបអូស (មាត្រា ៣៨១ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

---

[61] មាត្រា ២៥៩ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[62] មាត្រា ២៦៦ កថាខណ្ឌទី ៣ នៃក្រមដដែល

- ដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា ៥១៩ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលើកចោលការទាមទារអោយចែកចំណែក (មាត្រា ៥០៩ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ (មាត្រា ៥៧៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា ៣៥៥ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា ៣៥៥ កថាខណ្ឌទី ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

**ខ. ដីកាសម្រេចអនុញ្ញាត មិនអនុញ្ញាត និងបញ្ជា**

- ដីកាសម្រេចនូវការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យចូលអន្តរាគមន៍ (មាត្រា ៥៥ កថាខណ្ឌ ទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចបង្គាប់ឲ្យដាក់ប្រាតិភោគ (មាត្រា៦៧ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចឱ្យជួយសង្គ្រោះលើពាក្យបណ្ដឹង (មាត្រា ៧០ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចបង្គាប់ឲ្យនាំខ្លួនសាក្សី និងដីកាសម្រេចពិន័យសាក្សីជាសាច់ប្រាក់ដោយមិនចូលតាមដីកាកោះ (មាត្រា ១៣២ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចពិន័យភាគីដែលបន្លំសេចក្ដីថ្លែងការណ៍ (មាត្រា ១៤០ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចបង្គាប់ឲ្យផ្ដល់ឯកសារ (មាត្រា១៥២ កថាខណ្ឌទី៣ នៃក្រមនីតិវិធី រដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យតតិយជនបង់ប្រាក់ពិន័យដោយមិនគោរពដីកាសម្រេចបង្គាប់ឲ្យផ្ដល់ឯកសារ (មាត្រា ១៥៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឲ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា ៣៥៥ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចអនុញ្ញាតឲ្យរឹបអូស (មាត្រា ៣៨១ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

- ដីកាសម្រេចបង្គាប់ឲ្យប្រគល់ចលនវត្ថុដែលត្រូវរឹបអូស (មាត្រា ៣៩០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុល (មាត្រា ៤១៣ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ (មាត្រា ៤៧៥ នៃក្រមនិតិវិធី រដ្ឋប្បវេណី) ។
- ដីកាសម្រេចឲ្យប្រគល់នាវា (មាត្រា ៤៨៣ កថាខណ្ឌទី ៤ នៃក្រមនីតិវិធី រដ្ឋប្បវេណី) ។
- ដីកាសម្រេចអនុញ្ញាតឲ្យយកវត្ថុបញ្ចាំមកសងផ្ទាល់ (មាត្រា ៥០៤ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ។

**គ. ដីកាសម្រេចផ្សេងៗ**

- ដីកាសម្រេចផ្ទេរសិទ្ធិ និងដីកាសម្រេចលើបណ្ដឹង (មាត្រា ២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចសេចក្ដីថា ការដកហូត ឬបណ្ដឹងជិតចិត្តពុំត្រឹមត្រូវ (មាត្រា ៣០ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចអំពីពាក្យសុំឲ្យតុលាការបង្គាប់ឲ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដីដោយដើមចោទគ្មានទីលំនៅច្បាស់លាស់ ឬពិតប្រាកដ (មាត្រា៦៧ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ (មាត្រា ១៩៥ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចកែតម្រូវសាលក្រម (មាត្រា ១៩២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី (មាត្រា ៣១៥ នៃក្រមនីតិវីធីរដ្ឋប្បវេណី) ។

## កថាខណ្ឌទី ៣៖ វិសាលភាពនៃបណ្ដឹងជំទាស់

ក្នុងកថាខណ្ឌនេះនឹងធ្វើការបកស្រាយអំពីចំណុច ការប្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ និង ការប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ហា ឬការប្រគល់សិទ្ធិ ។

### ១) ការប្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍

បើទោះបីជាការប្ដឹងជំទាស់អាចធ្វើឡើងតាមការកំណត់បញ្ញត្តិច្បាប់ក៏ដោយ ក៏ប៉ុន្តែចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្ដឹងជំទាស់ ដែលតុលាការនៃបណ្ដឹងជំទាស់ចេញគឺមិនអាចប្ដឹងជំទាស់ទៀតបានទេ ។ ការអនុវត្តបែបនេះគឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល ។ ឧទាហរណ៍ ក្នុងករណីដែលមានបណ្ដឹងជំទាស់ចំពោះដីកាសម្រេចបង្គាប់ឲ្យផ្ដល់ឯកសារដែល

បានចេញដោយសាលាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១[63] ភាគីមិនអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចចុងក្រោយអំពីបណ្ដឹងជំទាស់របស់សាលាឧទ្ធរណ៍ដែលជាតុលាការនៃបណ្ដឹងជំទាស់នោះទៅតុលាការកំពូលថែមទៀតបានឡើយ ។

ផ្ទុយទៅវិញ ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្ដឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាតឲ្យប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ ។ បណ្ដឹងជំទាស់នេះ គឺជាបណ្ដឹងជំទាស់ទៅតុលាការកំពូលដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្ដឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះគឺស្រដៀងគ្នាទៅនឹងការអនុវត្តចំពោះបណ្ដឹងសាទុក្ខចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការជំនុំជម្រះលើកទី ១ ។ ដោយហេតុនេះ បញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីទាក់ទងទៅនឹងការជំនុំជម្រះបណ្ដឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាចំពោះបណ្ដឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និងនីតិវិធីដែលទាក់ទងនឹងបណ្ដឹងជំទាស់ទាំងនោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹង ឬនីតិវិធីនោះ[64] ។ ហេតុដូច្នេះ នៅក្នុងករណីនេះ បណ្ដឹងជំទាស់អាចធ្វើទៅបានដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើម ។

ម៉្យាងវិញទៀត មានករណីខ្លះដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។ ក្នុងករណីនេះ ភាគីមិនអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍ទេ បើពុំមានបញ្ញតិច្បាប់អនុញ្ញាតឱ្យប្ដឹងជំទាស់[65] ។

**២) ការប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬការប្រគល់សិទ្ធិ**

ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬចៅក្រមទទួលបន្ទុក ( ឧទាហរណ៍ ដីកាសម្រេចទៅលើការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី[66]) នេះគឺខុសគ្នានឹងដីកាសម្រេចរបស់តុលាការ ដោយនៅទីនេះគេតម្រូវអោយមានការគ្រប់គ្រងពិនិត្យដោយតុលាការដែលទទួលបណ្ដឹង ។ ហេតុនេះ បើភាគីមានសេចក្ដីតវ៉ា តុលាការដែលទទួលបណ្ដឹងត្រូវសម្រេចសេចក្ដីដោយដីកាសម្រេច ។

[63] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[64] មាត្រា ៣០៤ កថាខណ្ឌទី ២ នៃក្រមដដែល

[65] មាត្រា ២៥៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[66] មាត្រា ១៣៥ នៃក្រមដដែល

ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬចៅក្រមទទួលបន្ទុកដែលត្រូវបានជ្រើសតាំង ចំពោះរឿងក្ដីដែលសាលាឧទ្ធរណ៍ ឬតុលាការកំពូលកំពុងចាត់ការវិញ ក៏ដូចគ្នានឹងករណីដែលសាលាដំបូងជាតុលាការទទួលបណ្ដឹង ដែលភាគីអាចដាក់ពាក្យសុំប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល ដែលជាតុលាការទទួលបណ្ដឹង ។

ចំពោះការស្នើសុំប្ដឹងតវ៉ាដែលមានចែងក្នុងមាត្រា ៣០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដីកាសម្រេចនោះត្រូវបានធ្វើឡើងដោយតុលាការទទួលបណ្ដឹង នោះភាគីត្រូវធ្វើបណ្ដឹងជំទាស់ ហេតុនេះភាគីត្រូវធ្វើបណ្ដឹងតវ៉ា នៅក្នុងអំឡុងពេល ១ សប្ដាហ៍ក្រោយថ្ងៃទទួលដំណឹងអំពីដីកាសម្រេចដែលមានចែងក្នុងមាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ។

ប្រសិនបើតុលាការទទួលបណ្ដឹងជាសាលាឧទ្ធរណ៍ ចំពោះតែករណីនៃកថាខណ្ឌទី ២ នៃមាត្រា ៣០៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ) អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើពាក្យសុំដែលមានចែងក្នុង កថាខណ្ឌទី ១ មាត្រា ៣០២ បាន តែប្រសិនបើតុលាការទទួល ពាក្យបណ្ដឹងជាតុលាការកំពូលវិញ មិនអាចប្ដឹងជំទាស់បានឡើយ ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាបកស្រាយលើប្រធានបទស្តីពី បណ្តឹងឧបាស្រ័យ រួចមក ការស្រាវជ្រាវនេះផ្តោតលើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មាន ៣ ប្រភេទ ដែលភាគីអាចជ្រើសរើសស្របទៅតាមចំណាត់ការរបស់តុលាការ ។ ក្នុងនោះផងដែរ បណ្តឹងឧបាស្រ័យមាន បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ ។ ក្នុងចំណោមបណ្តឹងទាំងបីនេះ បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ប្តឹងចំពោះសាលក្រម និងសាលដីកា រីឯបណ្តឹងជំទាស់វិញធ្វើឡើងចំពោះសាលដីកាសម្រេច ។

ជាទូទៅពេលដែលភាគីបានដាក់ពាក្យបណ្តឹងជំទាស់លើដីកាសម្រេច ឬដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ នោះអានុភាពនៃការដាក់ពាក្យបណ្តឹងឧបាស្រ័យនឹងកើតមានឡើង ។ អានុភាពនៃការដាក់បណ្តឹងឧបាស្រ័យមាន ៣ គឺអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម អានុភាពនៃការផ្ទេរការជម្រះក្តី និង ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ។

លើសពីនេះទៅទៀត នៅពេលដែលភាគីមិនពេញចិត្តលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ភាគីអាចប្តឹងឡើងទៅតុលាការកំពូលដែលជាតុលាការចុងក្រោយដើម្បីស្វែងរកយុត្តិធម៌ដល់គូភាគីដែលមិនសុខចិត្តលើសេចក្តីសម្រេចនោះ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរឿងរដ្ឋប្បវេណីដើម្បីសម្រាលបន្ទុកតុលាការកំពូល ភាគីមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ទៀតទេ ។

ដូច្នេះយើងឃើញថា បណ្តឹងឧបាស្រ័យពិតជាភាពស្មុគស្មាញនៅក្នុងដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី និងធ្វើឱ្យអ្នកច្បាប់មានការលំបាកក្នុងការអនុវត្តអោយស្របទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់« ។

ទោះបីជាមានការខិតខំប្រឹងប្រែងអនុវត្តការវិនិច្ឆ័យស្វែងរកយុត្តិធម៌ជូនភាគីវិវាទក៏ដោយ មន្ត្រីស្ថាប័នតុលាការមួយចំនួននៅមិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយតាមច្បាប់នីតិវិធីដែលបានកំណត់ ។ ពីព្រោះថា ពេលខ្លះដោយសារមានការមមាញឹកក្នុងការងារច្រើនពេក លោកក៏បានសម្រេចសេចក្តីដោយមិនបានគោរពគោលការណ៍នីតិវិធីពេញលេញឡើយ ឬក៏លោកធ្លាប់មានបទពិសោធន៍ក្នុងការងារច្រើនពេក ក៏សម្រេចធ្វើតាមអ្វីៗដែលលោកធ្លាប់តែអនុវត្ត ដោយមិនគិតពីនីតិវិធីចាំបាច់ឡើយ ។ អាស្រ័យហេតុនេះ ការស្រាវជ្រាវនេះសូមជូនជាអនុសាសន៍ដល់មន្ត្រីតុលាការ លោកគួរតែប្រតិបត្តិការងារផ្សំនឹងបទពិសោធន៍ ព្រមទាំងកុំឃ្លាតឆ្ងាយពីច្បាប់នីតិវិធីដែលបានកំណត់ផ្លូវសំរាប់ប្រតិបត្តិក្នុងវិស័យតុលាការ ។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- ក្រមនីតិវិធីរដ្ឋប្បវេណីដែលព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១: នីតិវិធីបណ្តឹង រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ។
- វចនានុក្រមខ្មែរ បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតលើកទី ៥ នៅឆ្នាំ ១៩៦៧ របស់សម្តេចពោធិញាណ **ជួន ណាត** ។

# ឧបសម្ព័ន្ធ

# ទម្រង់ពាក្យបណ្តឹង

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹង

**ដើមចោទ** ៖ លោក ..................... ជាតិ...... កើតឆ្នាំ ........... មានអាស័យដ្ឋានស្ថិតនៅ ផ្ទះលេខ ............ ផ្លូវលេខ ........ សង្កាត់............ ខណ្ឌ........... ខេត្ត/រាជធានី ................... ។

**សហចុងចម្លើយ** ៖ ១- ឈ្មោះ ........................... ភេទ..... ជាតិ...... កើតឆ្នាំ......... មានទីលំនៅ ភូមិ/ក្រុម........ ឃុំ/សង្កាត់............ ស្រុក/ខណ្ឌ................ខេត្ត/រាជធានី ..................... ។

២- ឈ្មោះ .......................... ភេទ...... ជាតិ..... កើតឆ្នាំ ..........មានទីលំនៅ ភូមិ/ក្រុម............. ឃុំ/សង្កាត់............ ស្រុក/ខណ្ឌ............... ខេត្ត/រាជធានី .......................។

## សូមគោរពជូន

## លោកប្រធានសាលាដំបូង......................

**កម្មវត្ថុ ៖** ស្នើសុំឲ្យសាលាដំបូង...................ចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម ៖

១- រំលាយចោលកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីចុះថ្ងៃទី.... ខែ..... ឆ្នាំ.......... ។

២- បង្គាប់ឲ្យសហចុងចម្លើយ ៖

ក. សងប្រាក់ដើមចំនួន ...................... ( .................................. ) និងការប្រាក់ចំនួន ..... % ក្នុងមួយខែគិតចាប់ពីថ្ងៃទី...... ខែ....... ឆ្នាំ........ រហូតដល់សងគ្រប់ចំនួន ។

២. សងថ្លៃខូចខាតពេលវេលា ជំងឺចិត្ត និងថ្លៃសេវាមេធាវីចំនួន...............................
(...................) ។

៣. ប្រាក់ពន្ធតុលាការ ប្រាក់ប្រដាប់ក្ដីតុលាការ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងពន្ធតុលាការផ្សេងៗទៀតជាបន្ទុករបស់ភាគីសហចុងចម្លើយ ។

៤. សុំអនុវត្តសាលក្រមបណ្ដោះអាសន្ន ។

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

- កិច្ចព្រមព្រៀងផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី.... ខែ..... ឆ្នាំ......... ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី..... ខែ...... ឆ្នាំ.......... ឈ្មោះ ............. និងឈ្មោះ ............ បានមកខ្ចីប្រាក់ខ្ញុំបាទចំនួន ....................... (.......................................) ក្នុងអត្រាការប្រាក់ចំនួន ..... % ក្នុងមួយខែ ដោយសន្យាខ្ចីចំនួន .......ខែ ។ គិតចាប់ពីថ្ងៃខ្ចីប្រាក់រហូតមកដល់ពេលនេះឈ្មោះខាងលើពុំដែលបានបង់ការប្រាក់ និងពុំបានសងប្រាក់ដើមមកឲ្យខ្ញុំបាទវិញនោះ បើគិតពីពេលកំណត់ត្រូវសងមកដល់ពេលនេះគឺមានរយៈពេល....................................... ទោះបីជាខ្ញុំបាទទាមទារឲ្យសងយ៉ាងណាក៏ដោយក៏ពួកគេនៅតែគេចវេសពុំព្រមសងនោះទេ ។ ទង្វើខាងលើនេះគឺជាការបំពានយ៉ាងធ្ងន់ធ្ងរលើកាតព្វកិច្ចនៃកិច្ចព្រមព្រៀងខ្ចីប្រាក់ និងធ្វើឲ្យខ្ញុំបាទទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមការស្នើសុំដូចមានចែងក្នុងកម្មវត្ថុខាងលើដោយក្ដីអនុគ្រោះ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ...... ឆ្នាំ.........

ស្នាមមេដៃស្ដាំ

....................

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំមេធាវី .................................. ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ................និង ឈ្មោះ ................ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ..............ចុះថ្ងៃទី ....ខែ .... ឆ្នាំ.............របស់ សាលាដំបូង.................................. ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូង**...............................

**កម្មវត្ថុ ៖** ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ................ ចុះថ្ងៃទី ..... ខែ ....... ឆ្នាំ............របស់ សាលាដំបូង ........................... ។

**យោង ៖**
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។
- សំណុំរឿងរដ្ឋប្បវេណីលេខ.................................... ចុះថ្ងៃទី ....... ខែ............ ឆ្នាំ............របស់ សាលាដំបូង ........................................ ។
- សាលក្រមលេខ ............................................................ ចុះថ្ងៃទី ....... ខែ............ ឆ្នាំ............របស់ សាលាដំបូង ...................................................................... ។
- លិខិតតំណាងដោយអាណត្តិចុះថ្ងៃទី...... ខែ..... ឆ្នាំ.............. ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី.....ខែ........ឆ្នាំ........... សាលាដំបូង........................បានចេញសាលក្រមលេខ ...................... ដោយបានសម្រេចច្រានចោលការទាមទាររបស់កូនក្តីខ្ញុំចោលទាំងស្រុង ។ ការសម្រេចសេចក្តីនេះ គឺជាការសម្រេចដ៏អយុត្តិធម៌បំផុតសម្រាប់កូនក្តីខ្ញុំដែលជាជនរងគ្រោះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាទទួល និងចុះបញ្ជីបណ្ដឹង ឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្ដីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី........ខែ.........ឆ្នាំ........

**ហត្ថលេខា និងឈ្មោះ**

...................

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹងសាទុក្ខ

**ដើមបណ្តឹងសាទុក្ខ ៖** លោក ............ ជាតិ.... កើតឆ្នាំ ........... និងប្រពន្ធឈ្មោះ .............. មានទីលំនៅបច្ចុប្បន្ន ..............................................................។

**ចុងបណ្តឹងសាទុក្ខ ៖** - លោក.....................ហៅ ............. ជាតិ....... មានទីលំនៅបច្ចុប្បន្ន ..........................................................................................។

- លោក .....................ហៅ ........... ជាតិខ្មែរ អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ............................................................... ។

- លោក ...................... ហៅ .................... ជាតិ...... អាយុ ..... ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ................................................................។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាឧទ្ធរណ៍

**កម្មវត្ថុ ៖** ប្តឹងសាទុក្ខនឹងសាលដីកាលេខ .................. ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់ .......................... ។

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

- សំណុំរឿងរដ្ឋប្បវេណីលេខ..........ចុះថ្ងៃទី.....ខែ......ឆ្នាំ..........របស់សាលាឧទ្ធរណ៍
- សាលដីកាលេខ........... ចុះថ្ងៃទី..... ខែ...... ឆ្នាំ.......... របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កាលពីថ្ងៃទី......ខែ..... ឆ្នាំ.......... សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ................ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ....... ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់មេធាវីឈ្មោះ ........................ អ្នកតំណាងដោយអាណាត្តិឲ្យសហចុងចម្លើយឈ្មោះ ....................... ឈ្មោះ ................. និងឈ្មោះ .................... ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។
- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី.... ខែ....... ឆ្នាំ........... របស់សាលាដំបូង.................ចោលជាអសារបង់ ។
- ច្រានពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ ......................... ចុះថ្ងៃទី..... ខែ....... ឆ្នាំ.......... ចោលជាអសារបង់ ។
- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

ការសម្រេចសេចក្ដីខាងលើនេះ គឺពិតជាបានផ្ដល់នូវភាពអយុត្តិធម៌ជាទីបំផុតដល់យើងខ្ញុំ ដែលជាជនរងគ្រោះដោយសារការរំលោភបំពានរបស់ភាគីចុងចម្លើយ ដែលយើងខ្ញុំពុំអាចទទួលយកបានទេ ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកបណ្ដឹងសាទុក្ខ និងចាត់ការតាមនីតិវិធីច្បាប់ដោយក្ដីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ...... ឆ្នាំ.........

ស្នាមមេដៃស្ដាំ

......................

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹងជំទាស់

ខ្ញុំបាទឈ្មោះ..................កើតនៅឆ្នាំ.........ជនជាតិ...... សញ្ជាតិ....... មានទីលំនៅបច្ចុប្បន្ន ..................................................................................................................................... ។

**សូមគោរពចូលមក**

**លោកប្រធានតុលាការដំបូង**.....................

**កម្មវត្ថុៈ** ប្តឹងជំទាស់លើដីកាសម្រេចលេខ...........ចុះថ្ងៃទី.......ខែ.......ឆ្នាំ........របស់សាលាដំបូង ......................... ។

**យោងៈ** - មាត្រា..........នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ។

- ដីការសម្រេចលេខ............ចុះថ្ងៃទី.....ខែ....ឆ្នាំ..........។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជូន **លោកប្រធាន** អោយបានជ្រាបថាៈ កាលពីថ្ងៃទី........ខែ........ឆ្នាំ............តុលាការឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើសំណុំរឿងលេខ ............ ចុះថ្ងៃទី.....ខែ........ឆ្នាំ.......... ។

ការសម្រេចសេចក្តីខាងលើនេះបានធ្វើអោយប៉ះពាល់ដល់ប្រយោជន៍ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ និងផ្តល់នូវភាពអយុត្តិធមិដល់រូបខ្ញុំបាទដែលជាជនរងគ្រោះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំបាទស្នើសុំ **លោកប្រធាន** មេត្តាទទួលនិងចាត់ការតាមនីតិវិធីច្បាប់ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី........ខែ........ ឆ្នាំ២០.........

ស្នាមមេដៃស្តាំ

................................